Tin Ponlok with contributions
from Bridget McIntosh and
Thanakvaro De Lopez



# ការប្រែប្រួលអាកាសធាតុ និង យន្តការអភិវឌ្ឍន៍ស្អាត

# CLIMATE CHANGE AND THE CLEAN DEVELOPMENT MECHANISM

ភ្នំពេញ ២០០៥

ក្រសួងបរិស្ថាន

CRCD

IGES
Institute for Global
Environmental Strategies,
Japan

មជ្ឈមណ្ឌលស្រាវជ្រាវកម្ពុជាដើម្បីអភិវឌ្ឍន៍
ប្រអប់សំបុត្រលេខ 2515
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
គេហទំព័រ : www.camdev.org
អ៊ីម៉ែល : webmaster@camdev.org

រូបថតក្របមុខ (ពីឆ្វេងមកស្តាំ ពីលើមកក្រោម) : ទឹកជំនន់ឆ្នាំ ២០០០ នៅខេត្តកណ្តាល, ស្រះស្រង់រីងស្ងួតនៅឆ្នាំ ២០០៤, ផ្សែងចេញពីរោងចក្រអគ្គិសនីមួយនៅភ្នំពេញ, ព្រះអាទិត្យរះនៅខេត្តសៀមរាប, បុគ្គលិក មសកអ ធ្វើការសាកល្បងតួប៊ីនដើរដោយកំលាំងខ្យល់, បន្ទះកញ្ចក់ស្រូបពន្លឺព្រះអាទិត្យនៃរោងចក្រអគ្គិសនីដើរដោយថាមពលព្រះអាទិត្យ និងជីវៈឧស្ម័ន កំលាំង ១២០ គីឡូវ៉ាត់ នៅក្បែរក្រុងព្រះសីហនុ (ថតដោយ ទិន ពន្លក) ។

រូបផ្ទៃខាងក្រោយ : ព្រះអាទិត្យរះនៅខេត្តសៀមរាប ។

# ការប្រែប្រួលអាកាសធាតុ
# និង
# យន្តការអភិវឌ្ឍន៍ស្អាត


រៀបរៀងដោយ ទិន ពន្លក

ពិនិត្យកែសំរួលដោយ ប្រ៊ីដជេត ម៉ាគីនតូស និង ឋានៈវ៉ារ៉ូ ដីឡូប៉េ

បកប្រែជាភាសាខ្មែរដោយ ម៉ម កុសល



២០០៤

ក្រសួងបរិស្ថាន

CRCD

IGES
Institute for Global Environmental Strategies, Japan

## បញ្ជីមាតិកា


បុព្វកថា ........................................................................... 1
១. សេចក្តីផ្តើម ........................................................................... 2
២. កំណើនកំដៅសកល និងការប្រែប្រួលអាកាសធាតុ ........................... 2
ផលផ្ទះកញ្ចក់ ........................................................................... 3
៣. ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ........................... 6
ផលប៉ះពាល់កំរិតពិភពលោក ........................................................... 6
ផលប៉ះពាល់នៅតំបន់អាស៊ីអាគ្នេយ៍ ........................................................... 12
ផលប៉ះពាល់ដល់ប្រទេសកម្ពុជា ........................................................... 13
៤. ការឆ្លើយតបរបស់មនុស្សទៅនឹងការប្រែប្រួល
អាកាសធាតុ : អនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ
និងពិធីសារក្យូតូ ........................................................................... 14
៥. ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ........................... 19
៦. បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ........................... 23
ធនធានទឹក ........................................................................... 24
កសិកម្ម ........................................................................... 25
សុខភាពមនុស្ស ........................................................................... 25
តំបន់ឆ្នេរ ........................................................................... 26
ព្រៃឈើ និងប្រព័ន្ធអេកូឡូស៊ី ........................................................... 26
គ្រោះមហន្តរាយអាកាសធាតុ និងបាតុភូតអាកាសធាតុមិនប្រក្រតី ........ 27
៧. សកម្មភាពក្នុងវិស័យប្រែប្រួលអាកាសធាតុនៅកម្ពុជា 27
កម្ពុជា និងអនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ ........................... 27
កម្ពុជា និងយន្តការអភិវឌ្ឍន៍ស្អាត ........................................... 28
ផលចំណេញនៃ CDM សំរាប់កម្ពុជា ........................................... 30
សក្តានុពលគំរោង CDM នៅកម្ពុជា ........................................... 31
ការរៀបចំផ្នែកស្ថាប័ន CDM នៅកម្ពុជា ........................................... 32
សន្ទានុក្រម ........................................................................... 35
ឯកសារយោង ........................................................................... 37

# បុព្វកថា

កូនសៀវភៅស្តីពីការប្រែប្រួលអាកាសធាតុ និងយន្តការអភិវឌ្ឍន៍ស្អាតនេះ ត្រូវបានចងក្រងឡើង ក្រោមការគាំទ្រផ្នែកថវិកា ពីវិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានពិភពលោក (Institute for Global Environmental Strategies: IGES) របស់ប្រទេសជប៉ុន តាមរយៈគំរោងមួយឈ្មោះ ការពង្រឹងសមត្ថភាពចំរុះសំរាប់យន្តការអភិវឌ្ឍន៍ស្អាត (Integrated Capacity Strengthening for the Clean Development Mechanism: ICS-CDM) ។ គំរោង ICS-CDM មានគោលដៅរួម ដើម្បីជួយបណ្តាប្រទេសមានសក្តានុពលជាម្ចាស់គំរោងយន្តការអភិវឌ្ឍន៍ស្អាត និងវិនិយោគិនជប៉ុន ឱ្យចូលរួមអនុវត្តគំរោងយន្តការអភិវឌ្ឍន៍ស្អាតនានា ដែលរួមចំណែកក្នុងការអភិវឌ្ឍន៍ដោយចីរភាព ។ គំរោងនេះមានគោលបំណងពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស នៅប្រទេសជាម្ចាស់ផ្ទះ ក្នុងការអនុវត្តន៏គំរោងយន្តការអភិវឌ្ឍន៍ស្អាត តាមរយៈ : (១) ការផ្សព្វផ្សាយព័ត៌មាន និងការលើកកំពស់ការយល់ដឹងស្តីពីយន្តការអភិវឌ្ឍន៍ស្អាត (២) ការកសាងបណ្តាញទាក់ទងក្នុងចំណោមភាគីពាក់ព័ន្ធនឹងយន្តការអភិវឌ្ឍន៍ស្អាត នៅប្រទេសជាម្ចាស់ផ្ទះ និងនៅប្រទេសជប៉ុន (៣) ការបណ្តុះបណ្តាលមន្ត្រីសំរាប់អនុវត្តយន្តការអភិវឌ្ឍន៍ស្អាត និង (៤) ការគាំទ្រដល់ការកំណត់ ការរៀបចំ និងការអនុវត្តន៏គំរោងយន្តការអភិវឌ្ឍន៍ស្អាត ។

កូនសៀវភៅនេះមានគោលបំណងលើកកំពស់ការយល់ដឹង ស្តីពីការប្រែប្រួលអាកាសធាតុ និងយន្តការអភិវឌ្ឍន៍ស្អាត ក្នុងចំណោមមន្ត្រីរាជការរបស់ក្រសួងពាក់ព័ន្ធ ក្រុមហ៊ុនឯកជន គ្រឹះស្ថានសិក្សាស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល និងសាធារណជនទូទៅ ។ បណ្ឌិត ទិន ពន្លក ជាអ្នករៀបរៀងសេចក្តីព្រាងទីមួយនៃកូនសៀវភៅនេះ ។ បណ្ឌិត ឋានៈរ៉ាវ៉ូ ដឺឡូប៉េ និងអ្នកស្រី ប្រ៊ីដជេត ម៉ាគីនតូស បានជួយផ្តល់នូវមតិ យោបល់ដ៏មានតម្លៃ ដល់សេចក្តីព្រាងនេះ ។

## ១. សេចក្តីផ្តើម

ក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ យើងតែងបានឮជាញឹកញាប់នូវពាក្យ "ការប្រែប្រួលអាកាសធាតុ" ។ តើបាតុភូតនេះជាអ្វី ? តើអ្វីខ្លះជាមូលហេតុនៃការប្រែប្រួលអាកាសធាតុ ? តើវាបង្កផលប៉ះពាល់អ្វីខ្លះ ? តើមនុស្សជាតិមានប្រតិកម្មតបបែបណា ? ហើយតើបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាកម្ពុជា អាចធ្វើអ្វីបានខ្លះ ដើម្បីជួយដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ? កូនសៀវភៅនេះនឹងផ្តល់ចំលើយខ្លះៗ ចំពោះសំនួរខាងលើ ។

## ២. កំណើនកំដៅសកល និងការប្រែប្រួលអាកាសធាតុ

បរិយាកាសនៅជុំវិញភពផែនដីយើង មាននាទីជាគំរបការពារភាវៈមានជីវិតទាំងអស់នៅលើផែនដី ។ បរិយាកាសផ្តល់នូវឧស្ម័នកាបូនិច ($CO_2$) សំរាប់ឱ្យរុក្ខជាតិធ្វើរស្មីសំយោគ និងអុកស៊ីសែន ($O_2$) សំរាប់សត្វ និងមនុស្សដកដង្ហើម ។ វាក៏ជួយការពារយើង ទល់នឹងឥទ្ធិពលប្រកបដោយគ្រោះថ្នាក់នៃកាំរស្មីពីលំហអវកាស ព្រមទាំងទល់នឹងការប៉ះទង្គិចដោយផ្ទាល់ពីអាចម៍ផ្កាយនានាមកពីលំហអវកាសខាងក្រៅ ដោយសារវាស្រូបកាំរស្មីទាំងនោះភាគច្រើន និងបំបែកបំផ្លាញអាចម៍ផ្កាយតាមរយៈការកកិតនឹងខ្យល់ ។

នៅក្នុងប្រវត្តិសាស្ត្រ អាកាសធាតុតែងកំណត់ពីរបៀបរស់នៅរបស់មនុស្ស ជាអាទិ៍ របៀបសង់ផ្ទះ ប្រភេទសំលៀកបំពាក់ ការបរិភោគ ទំលាប់ធ្វើកសិកម្ម ហើយអ្នកខ្លះថែមទាំងជឿថា អធ្យាស្រ័យរបស់មនុស្សក៏ត្រូវបានកំណត់ដោយអាកាសធាតុផងដែរ ។ ផ្ទុយទៅវិញ មានកត្តាជាច្រើនដែលជះឥទ្ធិពលទៅលើអាកាសធាតុ ដូចជា ការបញ្ចេញរស្មី និងទីតាំងព្រះអាទិត្យធៀបនឹងផែនដី ដំណើរវង្វិលជុំនៃផែនដី កូអ័រដោនេភូមិសាស្ត្រ សមាសភាពគីមីនៃម៉ាសខ្យល់ ចំងាយពីសមុទ្រ ទំហំសមុទ្រ និងសណ្ឋានដីជាដើម ។ ជាពិសេសកត្តាទាំងនេះមានឥទ្ធិពលលើសីតុណ្ហភាព ព្រមទាំងបរិមាណ និងរបាយទឹកភ្លៀង ដែលជាធាតុដ៏

សំខាន់បំផុតពីរនៃអាកាសធាតុនៅតំបន់ណាមួយជាក់លាក់ ។ ការប្រែប្រួលកត្តាទាំងនេះនឹងនាំឱ្យមានការប្រែប្រួលអាកាសធាតុពិភពលោក ។ ជាផលវិបាក វានឹងនាំឱ្យមានផលប៉ះពាល់ដល់របៀបរស់នៅរបស់យើង ។

នៅក្នុងរយៈកាលភាគច្រើននៃប្រវត្តិសាស្ត្រមនុស្សជាតិ ការប្រែប្រួលអាកាសធាតុផែនដីបានកើតឡើង ដោយសារមូលហេតុធម្មជាតិ ដែលបានបន្តជាច្រើនរយ ឬច្រើនពាន់ឆ្នាំ ។ ប៉ុន្តែ ចាប់តាំងពីមានបដិវត្តន៍ឧស្សាហកម្មជាង ២០០ ឆ្នាំ មុននេះ សកម្មភាពនានារបស់មនុស្សបានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរ និងជាបន្ទាន់មកលើអាកាសធាតុ ពោលគឺកំណើនការបញ្ចេញចោលនូវឧស្ម័នផ្ទះកញ្ចក់ (greenhouse gases: GHG) ទៅក្នុងបរិយាកាសកំពុងបង្កើនសំទុះនៃបាតុភូតធម្មជាតិមួយ ដែលហៅថា ផលផ្ទះកញ្ចក់ (greenhouse effect) ។ បាតុភូតនេះនាំឱ្យមានកំណើននៅក្នុងអំឡុងពេលវែង នូវសីតុណ្ហភាពមធ្យមរបស់ផែនដី ដែលហៅថា កំណើនកំដៅសកល (global warming) ។

## ផលផ្ទះកញ្ចក់

ផ្ទះកញ្ចក់គឺជាផ្ទះមួយដែលមានដំបូល និងជញ្ជាំងធ្វើពីផ្លាស្ទិច ឬកញ្ចក់ថ្លា ដែលត្រូវបានសាងសង់ឡើងសំរាប់ដាំបន្លែ ផ្កា ឬរុក្ខជាតិផ្សេងទៀត នៅក្នុងបណ្តាប្រទេសនៃតំបន់ត្រជាក់បង្គួរ និងតំបន់ត្រជាក់ ។ ផ្ទះកញ្ចក់មាននាទីការពារ និងផ្តល់កំដៅដល់រុក្ខជាតិ : ដំបូល និងជញ្ជាំងរបស់វាអាចឱ្យពន្លឺព្រះអាទិត្យចាំងចូលបាន ប៉ុន្តែរាំងស្កាត់មិនឱ្យកំដៅភាយចេញវិញ ។ បាតុភូតនេះត្រូវបានឱ្យឈ្មោះថា **“**ផលផ្ទះកញ្ចក់**”** ។

បរិយាកាសជុំវិញផែនដីផ្សំដោយឧស្ម័នមួយចំនួន ហៅថាឧស្ម័នផ្ទះកញ្ចក់ ដែលកើតឡើងដោយធម្មជាតិ ជាអាទិ៍ ចំហាយទឹក ឧស្ម័នកាបូនិច មេតាន ($CH_4$) ឌីអាសូតម៉ូណូអុកស៊ីត ($N_2O$) និងអូសូន ($O_3$) ។ ស្រទាប់ឧស្ម័នទាំងនេះ ដែលមានវត្តមាននៅក្នុងបរិយាកាសដោយធម្មជាតិ បំពេញនាទីជាដំបូលផ្ទះកញ្ចក់មួយ

ហើយរក្សាកំដៅទុកនៅជិតផ្ទៃផែនដី ។ ជាលទ្ធផល បាតុភូតនេះជួយរក្សានូវសីតុណ្ហភាពមធ្យមនៃផ្ទៃផែនដីក្នុងកំរិតប្រមាណ 16ºC ដែលជាកត្តាសំខាន់បំផុតសំរាប់ធានាឱ្យមាននូវលក្ខខណ្ឌអាកាសធាតុសមស្រប អាចទ្រទ្រង់ជីវិតសត្វ និងរុក្ខជាតិនៅលើផែនដីបាន ។

ចាប់តាំងពីបដិវត្តន៍ឧស្សាហកម្មមក សកម្មភាពមនុស្សបានបង្កឱ្យមានកំណើនកំហាប់ឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាសជាខ្លាំង ។ ឧស្ម័នផ្ទះកញ្ចក់ចំបង១ និងប្រភពនៃការបញ្ចេញឧស្ម័នទាំងនេះគឺ :

- ឧស្ម័នកាបូនិច មានប្រភពពីដំណុតឥន្ធនៈផូស៊ីល (ធ្យូងថ្ម ប្រេង ឧស្ម័នធម្មជាតិ) និងពីការបាត់បង់ព្រៃឈើ
- មេតាន មានប្រភពពីវាលស្រែ ការចិញ្ចឹមសត្វពាហនៈ កន្លែងចោលសំរាម សំណល់រាវពីគេហដ្ឋាន ការជីកយកធ្យូងថ្ម
- ឌីអាសូតម៉ូណូអុកស៊ីត មានប្រភពចំបងពីកាប្រើជីគីមីក្នុងកសិកម្មអតិផល និងពីដំណុតឥន្ធនៈផូស៊ីល
- អូសូនក្នុងបរិយាកាសជិតផ្ទៃផែនដី កើតដោយប្រយោលពីផ្សែងយាន-យន្ត
- ក្លរ៉ូភ្លុយអរ៉ូកាបូន (CFC) មានប្រភពពីកំប៉ុងថ្នាំបាញ់ និងមេត្រជាក់ប្រើក្នុងម៉ាស៊ីនត្រជាក់ និងទូទឹកកក ។

កំណើនកំហាប់ឧស្ម័នផ្ទះកញ្ចក់ក្នុងបរិយាកាសធ្វើឱ្យគំរប ឬ **"ដំបូល"** នៅជុំវិញផែនដីកាន់តែក្រាស់ ដែលធ្វើឱ្យវាអាចរាំងស្កាត់កំដៅកាន់តែច្រើនឡើងមិនឱ្យភាយចេញទៅក្នុងលំហអវកាសបាន ។ ប្រការនេះធ្វើឱ្យរំខានដល់តុល្យភាពនៃបណ្តូរកំដៅ និងបង្កឱ្យមានកំណើនសីតុណ្ហភាពខ្យល់ ដែលធ្វើឱ្យមានកំណើនកំដៅលើផ្ទៃផែនដី ។

នៅឆ្នាំ 1990 ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (The Inter-governmental Panel on Climate Change: IPCC) ដែលមានអ្នកវិទ្យាសាស្ត្រអន្តរជាតិប្រមាណ 2.500 នាក់ជាសមាជិក បានអះអាងថា

សកម្មភាពមនុស្សបានរួមចំណែកធ្វើឱ្យមានការប្រែប្រួលអាកាសធាតុ ។ ក្រុមការងារនេះក៏បានធ្វើការសន្និដ្ឋានដែរថា ប្រសិនបើនិន្នាការបច្ចុប្បន្ននៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅតែបន្ត នោះសីតុណ្ហភាពមធ្យមនៃពិភពលោកនឹងកើនឡើងប្រមាណ $3^{\circ}C$ នៅមុនដំណាច់សតវត្សរ៍ទី 21 ។




*ផលផ្ទះកញ្ចក់*

*ក) កាំរស្មីព្រះអាទិត្យឆ្លងកាត់បរិយាកាស ហើយកំដៅផ្ទៃផែនដី, ខ) ផ្ទៃផែនដីចាំងផ្លាតកំដៅទៅក្នុងបរិយាកាសវិញ ។ កំដៅមួយភាគចូលទៅដល់លំហអវកាស, គ) ឧស្ម័នផ្ទះកញ្ចក់ស្រូបយកកំដៅខ្លះ ហើយជះកំដៅត្រលប់ទៅផ្ទៃផែនដីវិញ, ឃ) នៅពេលដែលឧស្ម័នផ្ទះកញ្ចក់កើនកាន់តែច្រើនឡើងក្នុងបរិយាកាស កំដៅកាន់តែច្រើនក៏ត្រូវរាំងខ្ទប់នៅក្នុងបរិយាកាស ដែលបណ្តាលឱ្យមានកំណើនកំដៅសកល ។*

ការប្រែប្រួលអាកាសធាតុកំពុងបង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរ លើផលិតកម្មកសិកម្ម ធនធានទឹក សុខភាពមនុស្ស តំបន់ឆ្នេរ ព្រៃឈើ និងប្រព័ន្ធអេកូឡូស៊ី ។ គ្រោះទឹកជំនន់ ភាពរាំងស្ងួត ខ្យល់ព្យុះ និងគ្រោះមហន្តរាយផ្សេងទៀត ដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ បានកើតឡើងកាន់តែញឹកញាប់ និងខ្លាំងក្លា

ដោយបានបង្កឱ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរ នៅបណ្តាប្រទេសជាច្រើនលើពិភពលោក ។

## ៣. ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ

### ផលប៉ះពាល់កំរិតពិភពលោក

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ មិនបញ្ឈប់ត្រឹមព្រំដែនប្រទេសទេពោលគឺ ទាំងប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍន៍សុទ្ធតែរងគ្រោះដូចគ្នា ។ ប៉ុន្តែ បណ្តាប្រទេសកំពុងអភិវឌ្ឍន៍នឹងត្រូវរ៉ាប់រងបន្ទុកយ៉ាងធ្ងន់ធ្ងរនៃផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ។ នេះក៏ព្រោះតែភាពក្រីក្រធ្វើឱ្យប្រជាពលរដ្ឋងាយរងគ្រោះដោយសារប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ។ អ្នកក្រមិនមានសមត្ថភាព និងធនធានសមស្រប សំរាប់ដោះស្រាយ និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុឡើយ ។

ឧទាហរណ៍ : កំណើនកំពស់ទឹកសមុទ្រនឹងបង្កការគំរាមកំហែងដល់ប្រជាជននៅបណ្តាប្រទេសកោះ និងប្រទេសដែនដីសណ្តទាបៗ ដូចជាបង់ក្លាដែស អេហ្ស៊ីប និងចិន ជាដើម ។ ភាគច្រើននៃតំបន់ដែលប្រឈមនឹងគ្រោះថ្នាក់ស្ថិតនៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ដែលនៅទីនោះមានទីក្រុងធំៗក្នុងពិភពលោកប្រមាណ 30 តាំងនៅ ។ កំណើនកំដៅពិភពលោកនឹងប៉ះពាល់ដល់ការផ្គត់ផ្គង់ទឹក ហើយធ្វើឱ្យផលិតកម្មស្បៀងក្នុងតំបន់ត្រូពិច និងក្បែរត្រូពិចកាន់តែថយចុះ ជាទីដែលប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើនស្ថិតនៅ ដែលប្រការនេះនឹងនាំឱ្យប្រជាពលរដ្ឋជាច្រើនរយលាននាក់ប្រឈមនឹងគ្រោះទុរ្ភិក្សទៅអនាគត ។ កំណើនកំដៅនេះក៏ធ្វើឱ្យខូចខាតព្រៃក្រៅតំបន់ត្រូពិច នាំឱ្យបាត់បង់ប្រភេទនានា ព្រមទាំងធ្វើឱ្យជំងឺតំបន់ត្រូពិចរាតត្បាតទៅតំបន់ត្រជាក់បង្គួរ ។

**ភស្តុតាងខ្លះៗស្តីពីការប្រែប្រួលអាកាសធាតុ :**

- ភពផែនដីកំពុងកើនកំដៅយ៉ាងឆាប់រហ័ស ។ សីតុណ្ហភាពកំពុងកើនឡើងរហ័សជាងកំណើនដែលធ្លាប់មានក្នុងអំឡុងពេល 10.000 ឆ្នាំ កន្លងទៅ
- យោងតាមកំណត់ត្រា ទសវត្សរ៍ឆ្នាំទី 90 ជាទសវត្សរ៍ដែលក្តៅជាងគេ ហើយឆ្នាំ 1998 គឺជាឆ្នាំដែលក្តៅជាងគេ
- សីតុណ្ហភាពមធ្យមនៃផ្ទៃផែនដីបានកើនឡើងរវាងពី 0,3 ទៅ 0,6ºC នៅក្នុងអំឡុងពេល 100 ឆ្នាំចុងក្រោយ ។ សីតុណ្ហភាពនេះអាចនឹងកើនឡើង 2ºC បន្ថែមទៀតនៅក្នុងអំឡុងពេល 100 ឆ្នាំខាងមុខ ប្រសិនបើយើងនៅតែបន្តបញ្ចេញឧស្ម័នផ្ទះកញ្ចក់តាមករិតដូចបច្ចុប្បន្ន
- នីវ៉ូទឹកសមុទ្របានកើនឡើងប្រមាណ 10-25 សង់ទីម៉ែត ក្នុងអំឡុង 100 ឆ្នាំចុងក្រោយ ដោយសារការរលាយទឹកកកនៅតំបន់ប៉ូល ។ គេបានព្យាករណ៍ថា នឹងមានកំណើនប្រមាណ 50 សង់ទីម៉ែតបន្ថែមទៀត ត្រឹមឆ្នាំ 2100
- ស្ថានភាពធាតុអាកាសមិនអាចព្យាករណ៍បាន និងមិនប្រក្រតីតែងតែកើតមានជាញឹកញាប់ ដូចជា ព្យុះសង្ឃរា ព្យុះភ្លៀង និងទឹកជំនន់ ជាដើម ។

*ប្រភព : Just a Lot of Hot Air? The Panos Institute, 2000. London, UK.*

ការប្រែប្រួលអាកាសធាតុបង្កឱ្យមានផលវិបាកបីចំបងគឺ : ការប្រែប្រួលរបបទឹកភ្លៀងក្នុងតំបន់ កំណើននីវ៉ូទឹកសមុទ្រ និងកំណើនសីតុណ្ហភាពមធ្យម ។ ប្រការទាំងនេះនឹងនាំឱ្យមានផលប៉ះពាល់ដល់ :

### ធនធានទឹក

ការប្រែប្រួលអាកាសធាតុនឹងនាំឱ្យមានការប្រែប្រួលវដ្តទឹក ។ កំណកអាកាសនឹងកើនឡើងនៅតំបន់ខ្លះ តែថយចុះនៅតំបន់ខ្លះទៀត ។ ប្រការនេះនឹងធ្វើឱ្យមានការប្រែប្រួលភាពញឹកញាប់ និងកំលាំងនៃទឹកជំនន់ និងគ្រោះរាំងស្ងួត ។

ភាពប្រែប្រួលនៃរដូវអាចជះឥទ្ធិពលលើរបាយបរិមាណទឹកក្រោមដី ក៏ដូចជាទឹកលើដី នៅក្នុងតំបន់ ។ គុណភាពទឹកក៏អាចផ្លាស់ប្តូរទៅតាមការប្រែប្រួលនៃបរិមាណ និងពេលវេលានៃការធ្លាក់ភ្លៀងផងដែរ ។ ការប្រែប្រួលសីតុណ្ហភាពទឹកអាចជះឥទ្ធិពលលើអត្រារស់រាន ភាពសំបូរបែប និងផលិតភាពនៃប្រព័ន្ធអេកូឡូស៊ីទឹកសាប ។ កំណើននីវ៉ូទឹកសមុទ្រនឹងជះឥទ្ធិពលលើការផ្គត់ផ្គង់ទឹកសាបក្នុងតំបន់ឆ្នេរ ដោយសារការជ្រៀតចូលនៃទឹកសមុទ្រ ។

ការថយចុះនៃបរិមាណទឹកសាបនឹងនាំឱ្យមានសំពាធជាបន្ថែម លើប្រជាជនកសិកម្ម និងបរិស្ថាន ។ ការប្រែប្រួលអាកាសធាតុប្រហែលជានាំមកនូវកំណើនភាពតានតឹង (stress) បណ្តាលពីការបំពុល កំណើនចំនួនប្រជាជន និងការលូតលាស់នៃសេដ្ឋកិច្ច ។ តំបន់ងាយរងគ្រោះជាងគឺ តំបន់ស្ងួត តំបន់ពាក់កណ្តាលស្ងួត តំបន់ឆ្នេរមានរយៈកំពស់ទាប ដែនដីសណ្ត និងកូនកោះ ។

### ***ផលិតកម្មកសិកម្ម***

សីតុណ្ហភាពខ្ពស់ និងការប្រែប្រួលរបបទឹកភ្លៀងនឹងជះឥទ្ធិពលលើទិន្នផល និងផលិតភាពដំណាំ ។ ទិន្នផលដំណាំអាចថយចុះ ដោយសារតំរូវការឱ្យមានការស្រោចស្រពច្រើនហួសហេតុ កំណើនកំពស់ទឹកភ្លៀងដែលបង្កឱ្យមានសំណឹកដី និងការហូរច្រោះដីជាតិដី ព្រមទាំងការខូចខាតដំណាំដោយសារកំណើនបាតុភាពអាកាសធាតុមិនប្រក្រតី ។ កំណើននីវ៉ូទឹកសមុទ្រក៏នឹងនាំឱ្យបាត់បង់ដីដាំដំណាំនៅកន្លែងមានរយៈកំពស់ទាបក្នុងតំបន់ឆ្នេរផងដែរ ។

ក្រុមដែលងាយរងគ្រោះជាងគេគឺប្រជាពលរដ្ឋដែលគ្មានដីធ្លី អ្នកក្រ និងអ្នកនៅតំបន់ដាច់ស្រយាល នៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ។ តាមធម្មតា ប្រទេសទាំងនេះមានហេដ្ឋារចនាសម្ព័ន្ធទន់ខ្សោយ មានលទ្ធភាពតិចតួចក្នុងការប្រើប្រាស់បច្ចេកវិទ្យា និងព័ត៌មាន ហើយប្រទេសខ្លះកំពុងស្ថិតក្នុងជំលោះប្រដាប់អាវុធទៀត

ផង ។ កត្តាទាំងនេះបង្កការលំបាកកាន់តែខ្លាំងសំរាប់ប្រជាពលរដ្ឋ ក្នុងការដោះស្រាយផលវិបាកក្នុងផ្នែកកសិកម្មបណ្តាលពីការប្រែប្រួលអាកាសធាតុ ។

### *សុខភាពមនុស្ស*

ផលប៉ះពាល់ដោយផ្ទាល់នៃការប្រែប្រួលអាកាសធាតុ ចំពោះសុខភាពមនុស្ស មានជាអាទិ៍ កំណើនភាពតានតឹងបណ្តាលមកពីកំដៅ កំណើនជំងឺសរសៃឈាមបេះដូង ប្រព័ន្ធដង្ហើម ប្រតិកម្មទាស់ (allergy) និងជំងឺឆ្លងតាមខ្យល់ ។ កំណើននៃភាពញឹកញាប់ និង/ឬ ប្រពលភាពនៃបាតុភូតធាតុអាកាសមិនប្រក្រតីអាចបង្កឱ្យមានការបាត់បង់ជីវិតមនុស្ស រងរបួស ប៉ះពាល់ដល់ផ្លូវចិត្ត និងបង្កការខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធសុខភាពសាធារណៈ ។ ជំងឺតំបន់ត្រូពិច ដូចជាគ្រុនចាញ់ និងគ្រុនឈាមទំនងជានឹងកើនឡើងផងដែរ ដោយសារកំណើនទីជំរកសំរាប់សត្វមូស និងភ្នាក់ងារចំលងរោគផ្សេងទៀត (សត្វល្អិត) នៅពេលសីតុណ្ហភាពកើនឡើង ។ រោគឆ្លងតាមអាហារ និងទឹកក៏នឹងកើនឡើងផងដែរ ដោយសារសីតុណ្ហភាពក្តៅជាងមុន បរិមាណទឹកផ្គត់ផ្គង់ថយចុះ និងការសាយកូននៃមីក្រូសារពាង្គកាយ ។

អ្នកក្រនឹងកាន់តែងាយរងគ្រោះ ដោយសារផលប៉ះពាល់ដល់សុខភាព ជាងអ្នកមាន ។ ប៉ុន្តែ បណ្តាប្រទេសអ្នកមានក៏នឹងកាន់តែងាយរងគ្រោះដែរ ជាពិសេសនៅពេលដែលប្រជាជនកាន់តែមានវ័យចាស់ ។

### *តំបន់ឆ្នេរ*

ការសង្កេតនានាបង្ហាញថា នីវ៉ូទឹកសមុទ្រមធ្យមលើពិភពលោកបានកើនឡើងពី 10 ទៅ 25 សង់ទីម៉ែត ក្នុងអំឡុងសតវត្សកន្លងទៅ ដែលជាទូទៅបណ្តាលមកពីកំណើនសីតុណ្ហភាពខ្យល់មធ្យមលើពិភពលោកប្រមាណ 0,3-0,6ºC ចាប់តាំងពីឆ្នាំ 1860 មក ។

គេបានព្យាករណ៍ថា ប្រសិនបើនិន្នាការកំណើនកំដៅពិភពលោកបច្ចុប្បន្ននៅតែបន្ត នោះនីវ៉ូទឹកសមុទ្រនឹងកើនឡើងប្រមាណពី 15 ទៅ 95 សង់ទីម៉ែត បន្ថែម

ទៀត រហូតដល់ឆ្នាំ 2100 ។ ប្រការនេះនឹងកើតឡើង ដោយសារការរីកមាឌនៃទឹកសមុទ្រនៅពេលឡើងកំដៅ និងការហូរចូលបន្ថែមនៃទឹកសាបបានមកពីការរលាយផែនទឹកកក និងទឹកកក ។

តំបន់ឆ្នេរដែលមានរយៈកំពស់ទាប និងបណ្តាកូនកោះ ងាយរងគ្រោះបំផុតដោយសារកំណើននីវ៉ូទឹកសមុទ្រ ។ គេបានព្យាករណ៍ថា កំណើននីវ៉ូទឹកសមុទ្រចំនួន 1 ម៉ែត អាចធ្វើឱ្យលិចលង់ផ្ទៃដីប្រទេសហូឡង់ចំនួន 6% ប្រទេសបង់ក្លាដែស 17,5% និងលើសពី 50% នៃបណ្តារដ្ឋកូនកោះនានា ។

### *ព្រៃឈើ និងប្រព័ន្ធអេកូឡូស៊ី*

ព្រៃឈើមាននាទីសំខាន់ណាស់នៅក្នុងប្រព័ន្ធអាកាសធាតុ ។ ព្រៃឈើគឺជាអាងផ្ទុកកាបូនដ៏ចំបង ។ វាក៏មានឥទ្ធិពលដោយផ្ទាល់លើអាកាសធាតុប្រចាំទីអាកាសធាតុតំបន់ និងអាកាសធាតុទ្វីបផងដែរ ដោយវាមានអានុភាពលើសីតុណ្ហភាពផ្ទៃដី រំហួតរំភាយចំហាយទឹក ចំណាំងផ្លាតនៃកំដៅ កំណកំណើតពពក និងកំណកអាកាស ។

សមាសភាព និងរបាយភូមិសាស្ត្រនៃប្រព័ន្ធអេកូឡូស៊ីនឹងប្រែប្រួល នៅពេលប្រភេទនីមួយៗមានប្រតិកម្មតបនឹងលក្ខខណ្ឌថ្មីនៃអាកាសធាតុ ។ ក្នុងពេលជាមួយគ្នានេះ ទីជំរកនឹងត្រូវរេចរឹល ហើយដាច់ជាបំណែកៗ ដោយសារការប្រែប្រួលអាកាសធាតុ ការបាត់បង់ព្រៃឈើ និងសំពាធផ្សេងទៀតលើបរិស្ថាន រួមគ្នា ។ ការវិនាសផុតពូជទំនងជានឹងកើនឡើង សំរាប់ប្រភេទរុក្ខជាតិ និងសត្វខ្លះៗ ដែលមិនអាចទប់ទល់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុបាន ។

កំណើនត្រឹមតែ 1ºC នៃសីតុណ្ហភាពមធ្យមលើពិភពលោកនឹងជះឥទ្ធិពលលើដំណើរការ និងសមាសភាពព្រៃឈើ ។ ប្រភេទព្រៃមួយចំនួនអាចបាត់បង់ទាំងស្រុងឯបន្សំថ្មីនៃប្រភេទមួយចំនួនអាចកើតមានឡើង ជាហេតុអាចនាំឱ្យមានការបង្កើតជាប្រព័ន្ធអេកូឡូស៊ីបែបថ្មី ។ កំណើនកំដៅពិភពលោកក៏អាចនាំឱ្យមានកំណើនកត្តាចង្រៃ ភ្នាក់ងារបង្ករោគ និងភ្លើងព្រៃនៅក្នុងប្រព័ន្ធអេកូឡូស៊ីព្រៃឈើផងដែរ ។




*ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដែលអាចកើតមាន*

### ***គ្រោះមហន្តរាយអាកាសធាតុ និងបាតុភូតអាកាសធាតុមិនប្រក្រតី***

អ្នកវិទ្យាសាស្ត្រជឿថា ការប្រែប្រួលអាកាសធាតុដែលបង្កដោយមនុស្ស ក៏ជាមូលហេតុនាំឱ្យអាកាសធាតុមិនប្រក្រតី និងមហន្តរាយអាកាសធាតុកើតមានជាញឹកញាប់ ជាពិសេសនៅប៉ុន្មានទសវត្សរ៍កន្លងទៅនេះ ដូចជា រលកកំដៅ គ្រោះទឹកជំនន់ ភាពរាំងស្ងួត ព្យុះភ្លៀងខ្លាំងៗ និងបាតុភូតអាកាសធាតុមិនប្រក្រតីផ្សេងទៀត ។ បាតុភូតទាំងនេះបង្កឱ្យមានការបាត់បង់ជីវិតមនុស្សរាប់ពាន់នាក់ និងនាំឱ្យ

មានការខូចខាតអស់ជាច្រើនពាន់លានដុល្លាអាមេរិក ក្នុងវិស័យកសិកម្ម លំនៅដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធ ឧស្សាហកម្ម ។ល។

### *ផលប៉ះពាល់នៅតំបន់អាស៊ីអាគ្នេយ៍*

ភាពក្រីក្រ និងដង់ស៊ីតេប្រជាជនខ្ពស់ ក្នុងបណ្តាប្រទេសជាច្រើននៅ អាស៊ីអាគ្នេយ៍ មានន័យថា ការប្រែប្រួលតែតិចតួចនៃផលិតភាពដី និងដំណាំ ក៏នឹងបង្កផលវិបាកធ្ងន់ធ្ងរផ្នែកសង្គម និងសេដ្ឋកិច្ចដែរ ។ កំណើននៃភាពតានតឹងបណ្តាលមកពីកំដៅ ការប្រែប្រួលរដូវកាល កំណើនសីតុណ្ហភាព ការប្រែប្រួលរបបទឹកភ្លៀង និងភាពស្ងួតហែងជាងមុននៃដី អាចនាំឱ្យមានការថយចុះនូវទិន្នផលកសិកម្មនៅបណ្តាប្រទេសក្នុងតំបន់ ។

ការគំរាមកំហែងធ្ងន់ធ្ងរបំផុតចំពោះជីវភាពរស់នៅ ប្រហែលជាបណ្តាលមកពីការជន់លិចលង់តំបន់ឆ្នេរ ដោយសារកំណើននីវ៉ូទឹកសមុទ្រ ។ នៅអាស៊ីអាគ្នេយ៍ តំបន់ឆ្នេរ និងតំបន់ទំនាប ដែលមានប្រជាជនរស់នៅកុះករ នឹងងាយរងគ្រោះយ៉ាងខ្លាំងដោយសារទឹកជំនន់ ។ តំបន់ទាំងនោះរួមមានផ្ទៃដីដែលមានជីជាតិបំផុតជាអាទិ៍ ដែនដីសណ្តទន្លេមេគង្គ និងទន្លេចៅប្រាយ៉ា និងទំនាបកណ្តាលជុំវិញបឹងទន្លេសាបនៅប្រទេសកម្ពុជា ជាដើម ។

ការបាត់បង់ឆ្នេរខ្សាច់បណ្តាលពីការលិចលង់ អាចបង្កផលប៉ះពាល់អវិជ្ជមានដល់ឧស្សាហកម្មទេសចរណ៍ ដែលជាប្រភពប្រាក់ចំណូលដ៏សំខាន់សំរាប់ប្រទេសជាច្រើននៅអាស៊ីអាគ្នេយ៍ ។

កំណើនយ៉ាងឆាប់រហ័សនៃចំនួនប្រជាជន និងការពង្រីកសកម្មភាពសេដ្ឋកិច្ចក្នុងតំបន់ បានដាក់សំពាធធ្ងន់ធ្ងររួចមកហើយទៅលើធនធានទឹក ។ ការថយចុះនៃបរិមាណទឹកបណ្តាលពីការប្រែប្រួលអាកាសធាតុ អាចបង្កឱ្យមានភាពតានតឹងកាន់តែខ្លាំងឡើងដល់មនុស្ស កសិកម្ម និងបរិស្ថាន ។ ជំលោះដណ្តើមធនធានទឹកប្រហែលជានឹងកាន់តែមានសភាពអាក្រក់ទៅ នៅក្នុងអាងទន្លេប្រកបដោយដីមាន

ជីជាតិ ដូចជាទន្លេមេគង្គ ក្នុងតំបន់ដែលមានកំណើនចំនួនប្រជាជនយ៉ាងឆាប់រហ័ស និងនៅតំបន់រាំងស្ងួត ។

ជាសង្ខេប ការប្រែប្រួលអាកាសធាតុនឹងបង្កឱ្យមានបញ្ហាបន្ថែមទៀត សំរាប់កសិករ និងប្រជាពលរដ្ឋក្រីក្រ ក្នុងប្រទេសជាច្រើននៅអាស៊ីអាគ្នេយ៍ ដែលជាអ្នកមានធនធានតិចតួចដើម្បីបន្សាំ ឬបង្វែទីកន្លែង ។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ជាអាទិ៍ ការថយចុះនៃធនធានទឹក ការរេចរឹលនៃដី ក៏ដូចជាការបាត់បង់ធនធានព្រៃឈើ និងដែនទេសាទ អាចជាមូលហេតុនាំឱ្យមានការបំផ្លិចបំផ្លាញជីវភាពរស់នៅរបស់ប្រជាជន ។

### *ផលប៉ះពាល់ដល់ប្រទេសកម្ពុជា*

ក្នុងនាមជាប្រទេសកសិកម្មក្រីក្រមួយ ប្រទេសកម្ពុជាងាយរងគ្រោះជាខ្លាំងដោយសារការប្រែប្រួលអាកាសធាតុ ។ កសិកម្មកម្ពុជា ដែលជាវិស័យសំខាន់មួយរបស់សេដ្ឋកិច្ចជាតិ ពឹងអាស្រ័យលើទឹកភ្លៀងធម្មជាតិ និងរបបទឹកជំនន់ប្រចាំឆ្នាំនៃទន្លេមេគង្គ ក៏ដូចជាបឹងទន្លេសាប ។ អាស្រ័យហេតុនេះ កសិកម្មនៅកម្ពុជាមានការពាក់ព័ន្ធយ៉ាងខ្លាំងជាមួយនឹងការប្រែប្រួលអាកាសធាតុប្រចាំទី ដែលអាចកើតមានក៏ដូចជារបបខ្យល់មូសុង ។ ទិន្នន័យពីរយៈពេលប្រាំឆ្នាំចុងក្រោយនេះបានបង្ហាញថា 70% នៃផលិតកម្មស្រូវដែលខូចខាត គឺបណ្តាលមកពីទឹកជំនន់ ហើយការខូចខាតប្រមាណ 20% ទៀតបណ្តាលមកពីគ្រោះរាំងស្ងួត ។

ក្នុងអំឡុងទសវត្សរ៍កន្លងទៅ ប្រទេសកម្ពុជាបានរងនូវផលប៉ះពាល់សង្គមសេដ្ឋកិច្ច និងបរិស្ថាន បណ្តាលមកពីទឹកជំនន់ គ្រោះរាំងស្ងួត និងខ្យល់ព្យុះ ដែលកើតឡើងមិនប្រក្រតី ធ្ងន់ធ្ងរ និងកាន់តែញឹកញាប់ ហើយដែលគេជឿថាមានការទាក់ទងនឹងការប្រែប្រួលអាកាសធាតុប្រចាំទី និងអាកាសធាតុពិភពលោក ។

ការសិក្សាមួយ ដែលបានធ្វើឡើងដោយក្រសួងបរិស្ថាននៃប្រទេសកម្ពុជានៅឆ្នាំ 2001 បានបង្ហាញថា រហូតដល់ឆ្នាំ 2100 កំពស់ទឹកភ្លៀងក្នុងប្រទេសកម្ពុជាអាចកើនឡើងពី 3% ទៅ 35% ធៀបនឹងលក្ខខណ្ឌបច្ចុប្បន្ន ឯសីតុណ្ហភាពអាច

នឹងកើនឡើងក្នុងរវាង 1,3°C-2,5°C ។ លក្ខខណ្ឌទាំងនេះ អាចនាំឱ្យមានកំណើនបាតុភូតអាកាសធាតុមិនប្រក្រតី ។

លើសពីនេះ កំណើនកំពស់ទឹកសមុទ្រនឹងមានផលប៉ះពាល់ធ្ងន់ធ្ងរលើតំបន់ឆ្នេរសមុទ្រប្រវែង 435 គីឡូម៉ែត និងលើមួយភាគធំនៃទំនាបទន្លេមេគង្គ និងប្រព័ន្ធអេកូឡូស៊ីបឹងទន្លេសាប ដែលជាបេះដូងនៃសេដ្ឋកិច្ច វប្បធម៌ និងបរិស្ថានរបស់ប្រទេសកម្ពុជា ។ ការសិក្សាដដែលនេះបានបង្ហាញថា កំណើនកំពស់ទឹកសមុទ្រមួយម៉ែតនឹងធ្វើឱ្យលិចលង់កន្លែងជាច្រើនក្នុងតំបន់ឆ្នេរប្រទេសកម្ពុជា ជាពិសេសនៅខេត្តកោះកុង ។ ផ្ទៃដីសរុបប្រមាណ 44 គីឡូម៉ែតការ៉េនៃទីរួមខេត្តកោះកុងនឹងត្រូវលិចលង់ជាអចិន្ត្រៃយ៍ ។ ប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាងគឺជាចំណែកធំជាងគេដែលត្រូវលិចលង់ ហើយប្រមាណ 56% នៃតំបន់តាំងលំនៅដ្ឋាននឹងត្រូវលិចទឹកផងដែរ ។

ប្រទេសកម្ពុជាក៏ងាយរងគ្រោះផងដែរខាងផ្នែកសុខភាព បណ្តាលពីការប្រែប្រួលអាកាសធាតុ ដោយសារទីតាំងភូមិសាស្ត្រ ភាពទន់ខ្សោយនៃប្រព័ន្ធសុខាភិបាល ភាពក្រីក្ររបស់ប្រជាពលរដ្ឋភាគច្រើន និងការយល់ដឹងកំរិតទាបរបស់ប្រជាពលរដ្ឋ អំពីវិធានការថែទាំសុខភាព ។

## ៤. ការឆ្លើយតបរបស់មនុស្សទៅនឹងការប្រែប្រួលអាកាសធាតុ : អនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ និងពិធីសារក្យូតូ

កំណើននៃការព្រួយបារម្ភអំពីការប្រែប្រួលអាកាសធាតុ បាននាំឱ្យមានកិច្ចប្រឹងប្រែងទូទាំងពិភពលោក ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ ។ ការសង្កេតវិទ្យាសាស្ត្រផ្នែកការប្រែប្រួលអាកាសធាតុ បានចាប់ផ្តើមនៅពាក់កណ្តាលសតវត្សរ៍ទី 20 ។ សន្និសីទស្តីពីអាកាសធាតុលើកទីមួយបានធ្វើឡើងនៅឆ្នាំ 1979 ដោយបានអំពាវនាវដល់រដ្ឋាភិបាលនានានៅជុំវិញពិភពលោកឱ្យ **"ដឹងជាមុន និងទប់ស្កាត់ការប្រែប្រួលអាកាសធាតុបណ្តាលមកពីមនុស្ស ដែលអាចបង្កឥទ្ធិពលអវិជ្ជមានចំពោះសុខុមាលភាពនៃមនុស្សជាតិ"** ។ នៅឆ្នាំ 1988 កម្មវិធីបរិស្ថាន

សហប្រជាជាតិ (United Nations Environment Programme: UNEP) និងអង្គការឧតុនិយមពិភពលោក (World Meteorological Organization: WMO) បានបង្កើត *ក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកកិច្ចការប្រែប្រួលអាកាសធាតុ* (Intergovernmental Panel on Climate Change: IPCC) ដើម្បីផ្តល់ការវាយតំលៃដែលអាចជឿទុកចិត្តបាន អំពីស្ថានភាពនៃចំណេះដឹងវិទ្យាសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុ ។ IPCC បានចេញរបាយការណ៍វាយតំលៃលើកទីមួយរបស់ខ្លួននៅឆ្នាំ 1990 ដោយបានអះអាងអំពីភ័ស្តុតាងវិទ្យាសាស្ត្រនៃការប្រែប្រួលអាកាសធាតុ ។

បួនឆ្នាំក្រោយមក ពោលគឺនៅឆ្នាំ 1992 ប្រទេសចំនួន 154 បានជួបប្រជុំគ្នានៅឯសន្និសីទពិភពលោកកំពូលនៅទីក្រុងរីយ៉ូដឺសានេរ៉ូ ប្រទេសប្រេស៊ីល ហើយបានសំរេចចុះហត្ថលេខាលើ *អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ* (United Nations Framework Convention on Climate Change: UNFCCC) ដែលបានចូលជាធរមាននៅឆ្នាំ 1994 ។ អនុសញ្ញានេះបង្កើតឱ្យមានជាក្របខ័ណ្ឌច្បាប់អន្តរជាតិ ដើម្បីដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុនៅលើពិភពលោក ។ គោលបំណងចុងក្រោយនៃអនុសញ្ញានេះគឺ *ធ្វើឱ្យមានតុល្យភាពកំហាប់ឧស្ម័នផ្ទះកញ្ចក់ក្នុងបរិយាកាស នៅត្រឹមកំរិតមួយ ដែលរាំងស្កាត់ការប្រែប្រួលប្រកបដោយគ្រោះថ្នាក់ចំពោះអាកាសធាតុ* ។

អនុសញ្ញានេះបានកំណត់នូវគោលការណ៍ណែនាំខ្លះៗ ជាអាទិ៍ :

- **"ការទទួលខុសត្រូវរួម តែមានកំរិតផ្សេងៗគ្នា តាមសមត្ថភាពរៀងៗខ្លួន"** នៃប្រទេសនានា ដោយពិចារណាអំពីកំរិតខុសៗគ្នានៃការបញ្ចេញឧស្ម័ន និងសមត្ថភាពខុសៗគ្នានៃប្រទេសទាំងនោះក្នុងការចាត់វិធានការឆ្លើយតប ។ នេះមានន័យថា បណ្តាប្រទេសជឿនលឿន ដែលមកទល់បច្ចុប្បន្នគឺជាអ្នកប្រព្រឹត្ត **"បទល្មើស"** ចំបង ត្រូវដើរតួឈានមុខក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័ន

- “តំរូវការដោយឡែក និងស្ថានភាពពិសេសនៃបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ពិសេសបណ្តាប្រទេសដែលងាយរងគ្រោះដោយសារផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ” (ឧទាហរណ៍ : បណ្តាប្រទេសជាកូនកោះ ឬប្រទេសដែលស្ថិតនៅរយៈកំពស់ទាប)
- គោលការណ៍ត្រៀមបង្ការជាមុន ដែលអនុញ្ញាតឱ្យគេចាត់វិធានការក្នុងស្ថានភាព “អវត្តមាននៃភាពច្បាស់លាស់ផ្នែកវិទ្យាសាស្ត្រ” បាន
- “សិទ្ធិ” ក្នុងការជំរុញការអភិវឌ្ឍន៍ដោយចីរភាព ។

លើសពីនេះ អនុសញ្ញាបានស្នើឱ្យភាគីនានារៀបចំ និងធ្វើសេចក្តីរាយការណ៍អំពីសារពើភ័ណ្ឌជាតិរបស់ខ្លួនពាក់ព័ន្ធនឹងការបញ្ចេញ និងការស្រូបយកឧស្ម័នផ្ទះកញ្ចក់ ហើយអនុសញ្ញាក៏ជំរុញឱ្យមានការផ្ទេរបច្ចេកវិទ្យា និងកម្មវិធីនានា ដើម្បីកាត់បន្ថយ និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ។

អនុសញ្ញានេះក៏ចែងផងដែរថា បណ្តាប្រទេសជឿនលឿនត្រូវផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួននៅក្រោមអនុសញ្ញានេះ ។

ប៉ុន្តែ អនុសញ្ញានេះមិនបានចែងអំពីកាតព្វកិច្ចជាក់លាក់ និងជាលក្ខណៈច្បាប់ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ឡើយ ។ ប្រការទាំងនេះមានចែងនៅក្នុងពិធីសារក្យូតូ (The Kyoto Protocol) ។ ពិធីសារក្យូតូត្រូវបានអនុម័តនៅក្នុងសន្និសីទលើកទីបីនៃបណ្តាភាគីជាសមាជិកអនុសញ្ញា (Third Conference of the Parties: CoP-3) ដែលបានប្រព្រឹត្តទៅនៅទីក្រុងក្យូតូ ប្រទេសជប៉ុន នាឆ្នាំ 1997 ។ ពិធីសារនេះបានដាក់កាតព្វកិច្ចឱ្យប្រទេសជឿនលឿនចំនួន 39 ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់ខ្លួនប្រមាណ 5% ធៀបនឹងកំរិតនៃការបញ្ចេញរបស់ប្រទេសទាំងនោះនៅឆ្នាំ 1990 ឱ្យបានក្នុងចន្លោះឆ្នាំ 2008 និង 2012 ។

ពិធីសារក្យូតូអនុញ្ញាតឱ្យបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ សំរេចគោលដៅរបស់ខ្លួន ដោយប្រើប្រាស់វិធីផ្សេង តាមរយៈ “យន្តការបត់បែនបាន” (Flexibility

Mechanism) ចំនួនបី ។ យន្តការទាំងនេះរួមមាន ពាណិជ្ជកម្មការបញ្ចេញឧស្ម័ន (Emissions Trading: ពាណិជ្ជកម្មឥណទាននៃការបញ្ចេញឧស្ម័នរវាងប្រទេសជឿនលឿន) ការអនុវត្តន៍រួមគ្នា (Join Implementation: ការផ្ទេរឥណទាននៃការបញ្ចេញឧស្ម័នរវាងប្រទេសជឿនលឿន ដែលភ្ជាប់ជាមួយគំរោងកាត់បន្ថយឧស្ម័នជាក់លាក់) និង *យន្តការអភិវឌ្ឍន៍ស្អាត* (The Clean Development Mechanism: CDM) ។ CDM គឺជាយន្តការតែមួយគត់ដែលពាក់ព័ន្ធជាមួយប្រទេសកំពុងអភិវឌ្ឍន៍ ។ យន្តការនេះអនុញ្ញាតឱ្យបណ្តាប្រទេសជឿនលឿនបំពេញចំណែកខ្លះនៃកាតព្វកិច្ចកាត់បន្ថយការបញ្ចេញឧស្ម័នរបស់ខ្លួន តាមរយៈគំរោងនានាក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដែលកាត់បន្ថយការបញ្ចេញឧស្ម័ន ឬស្រូបយកឧស្ម័ន $CO_2$ ពីក្នុងបរិយាកាស ។ ប្រការសំខាន់ដែលត្រូវកត់សំគាល់គឺថាគំរោងទាំងនេះត្រូវតែជួយឱ្យសំរេចនូវគោលដៅអភិវឌ្ឍន៍ដោយចីរភាព ដូចដែលប្រទេសម្ចាស់ផ្ទះទទួលអនុវត្តគំរោង CDM បានកំណត់ ។

| **ជំហានឆ្ពោះទៅសកម្មភាពឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ** | | |
|---|---|---|
| **ព្រឹត្តិការណ៍** | **កាលបរិច្ឆេទ និងទីកន្លែង** | **សមិទ្ធិផលចំបងៗ/ព្រឹត្តិការណ៍** |
| IPCC - របាយការណ៍លើកទីមួយ | 1990 | ការឯកភាពទូទៅជាអន្តរជាតិដែលផ្អែកលើវិទ្យាសាស្ត្រថា សកម្មភាពមនុស្សមានឥទ្ធិពលលើអាកាសធាតុ |
| UNFCCC | 1992, រីយ៉ូដឺសានេរ៉ូ ប្រទេសប្រេស៊ីល | • កំណត់កាតព្វកិច្ចសំរាប់សហគមន៍អន្តរជាតិដើម្បីធ្វើឱ្យមានតុល្យភាពនូវកំហាប់ឧស្ម័នផ្ទះកញ្ចក់ក្នុងបរិយាកាស<br>• ទទួលស្គាល់ការទទួលខុសត្រូវចំបងនៃប្រទេសឧស្សាហកម្ម និងការទទួលខុសត្រូវកំរិតផ្សេងគ្នានៃប្រទេសកំពុងអភិវឌ្ឍន៍ |
| CoP-1 | 1995, ប៊ែរឡាំង ប្រទេសអាល្លឺម៉ង់ | • បង្កើតលេខាធិការដ្ឋាន UNFCCC<br>• បង្កើតដំណាក់កាលសាកល្បងនៃ |

| ជំហានឆ្ពោះទៅសកម្មភាពឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ | | |
|---|---|---|
| ព្រឹត្តិការណ៍ | កាលបរិច្ឆេទ និង ទីកន្លែង | សមិទ្ធិផលចំបងៗ/ព្រឹត្តិការណ៍ |
| | | "សកម្មភាពអនុវត្តន៍រួមគ្នា" ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់<br>• ឯកភាពលើកាលវិភាគសំរាប់កំណត់គោលដៅកាត់បន្ថយជាក់លាក់របស់ប្រទេសឧស្សាហកម្ម |
| IPCC - របាយការណ៍លើកទីពីរ | 1995 | • បញ្ជាក់អំពីឥទ្ធិពលរបស់មនុស្សលើអាកាសធាតុ<br>• អះអាងថាហានិភ័យនៃការប្រែប្រួលអាកាសធាតុមានកំរិតធ្ងន់ធ្ងរ ដែលតំរូវឱ្យចាត់វិធានការការពារ |
| CoP-2 | 1996, ហ្សឺណែវ ប្រទេសស្វីស | • អនុម័តកិច្ចព្រមព្រៀង IPCC2 និង CoP-1<br>• សេចក្តីថ្លែងការថ្នាក់រដ្ឋមន្ត្រីនៅហ្សឺណែវ ដែលជាកំលាំងជំរុញសំរាប់ការចរចាជាបន្ត |
| CoP-3 | 1997, ក្យូតូ ប្រទេសជប៉ុន | ឯកភាពលើពិធីសារក្យូតូ ដោយកំណត់គោលដៅកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់សំរាប់ប្រទេសឧស្សាហកម្ម |
| CoP-4 | 1998, ប៊ុយណូសអ៊ែរ ប្រទេសអាហ្សង់ទីន | ឯកភាពលើផែនការសកម្មភាពសំរាប់អនុវត្តពិធីសារក្យូតូ រួមទាំងបែបបទសំរាប់ជំរុញការផ្ទេរបច្ចេកវិទ្យា |
| CoP-5 | 1999, បោន ប្រទេសអាល្លឺម៉ង់ | ភាពជឿនលឿនបន្ថែមលើការអនុវត្តន៍ពិធីសារក្យូតូ |
| CoP-6 វគ្គទី 1 និង CoP-6 | 2000, ឡាអេ ប្រទេសហូឡង់ (វគ្គទី 1)<br>2001, បោន ប្រទេស | • សហរដ្ឋអាមេរិចដកខ្លួនពីពិធីសារក្យូតូ<br>• ការស្តារ និងការដាំព្រៃឈើសំរាប់ CDM<br>• បែបបទ និងនីតិវិធីសំរាប់គំរោង CDM |

| ជំហានឆ្ពោះទៅសកម្មភាពឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ | | |
|---|---|---|
| ព្រឹត្តិការណ៍ | កាលបរិច្ឆេទ និង ទីកន្លែង | សមិទ្ធិផលចំបងៗ/ព្រឹត្តិការណ៍ |
| វគ្គទី 2 | អាល្លឺម៉ង់ (វគ្គទី 2) | ខ្នាតតូច<br>• អនុម័តមូលនិធិពិសេសសំរាប់ការប្រែប្រួលអាកាសធាតុ |
| IPCC - របាយការណ៍លើកទី 3 | 2001 | អះអាងថាកំណើនកំដៅពិភពលោកបានកើតឡើងលឿនជាងការរំពឹងទុកដោយសារតែសកម្មភាពរបស់មនុស្សជាចំបង |
| CoP-7 | 2001, ម៉ារ៉ាកេស ប្រទេសម៉ារ៉ុក | ឯកភាពលើកិច្ចព្រមព្រៀងម៉ារ៉ាកេស ដែលកំណត់បែបបទ និងនីតិវិធីសំរាប់ CDM |
| CoP-8 | 2002, ញូវដែលី ប្រទេសឥណ្ឌា | • អនុម័តសេចក្តីថ្លែងការណ៍ក្រុងញូវដែលីស្តីពីការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍន៍ដោយចីរភាព<br>• អនុម័តបទបញ្ជា និងនីតិវិធីសំរាប់ក្រុមប្រឹក្សាប្រតិបត្តិ CDM |
| "រីយ៉ូ+10" កិច្ចប្រជុំកំពូលពិភពលោក | 2002, យូហាណេស្បួ ប្រទេសអាហ្វ្រិចខាងត្បូង | សេចក្តីសង្ឃឹមថាពិធីសារក្យូតូនឹងត្រូវអនុម័ត និងចូលជាធរមាននៅពេលនោះ ពុំបានលេចចេញជារូបរាងឡើយ |
| CoP-9 | 2003, មីឡាន់ ប្រទេសអ៊ីតាលី | អនុម័តបែបបទ និងនីតិវិធីសំរាប់គំរោង CDM ក្នុងវិស័យព្រៃឈើ |

*ដកស្រង់ចេញពី Just a Lot of Hot Air? The Panos Institute, 2000. London, UK, និង A Guide to the Climate Change Process, UNFCCC Secretariat; and Earth Negotiation Bulletin, IISD*

## ៥. ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ

ជំពូកទី ២ បានពន្យល់អំពីមូលហេតុនៃការប្រែប្រួលអាកាសធាតុ ពោលគឺកំណើននៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលទប់ស្កាត់កំដៅឱ្យនៅក្នុងបរិយាកាស

ផែនដីច្រើនជ្រុល ។ ហេតុនេះ ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់គឺជាវិធីមួយ ដែលអាចជួយដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុបាន ។




*ប្រភេទថាមពលកើតឡើងវិញ*

ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ អាចធ្វើឡើងតាមរយៈការចាត់វិធានការនានា ដែលអាចកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដូចជាការប្តូរទៅប្រើប្រាស់ប្រភពថាមពលកើតឡើងវិញ (ព្រះអាទិត្យ ខ្យល់ វារីអគ្គិសនី ជីវៈម៉ាស ជីវៈឧស្ម័ន ភ្នំភ្លើង រលក ទឹកជោរ ។ល។) ការបង្កើនប្រសិទ្ធិភាពថាមពល ព្រមទាំងការអភិរក្ស និងការបង្កើនផ្ទៃដីព្រៃឡើងវិញ ។ ការប្រើប្រាស់វិធានការណា

ដែលផ្តល់អត្ថប្រយោជន៍ផ្សេងទៀត បន្ថែមលើការកាត់បន្ថយកំណើនកំដៅពិភពលោក គឺជាប្រការសំខាន់ ។ ឧទាហរណ៍ : ការដាំព្រៃឡើងវិញ ការប្តូរទៅប្រើប្រាស់ថាមពលកើតឡើងវិញ ឬប្រសិទ្ធិភាពថាមពល និងវិធានការអភិរក្សនឹងផ្តល់អត្ថប្រយោជន៍ជាច្រើនក្នុងផ្នែកបរិស្ថាន សេដ្ឋកិច្ច និងសង្គម ។ ប្រការនេះមានសារៈសំខាន់ណាស់ សំរាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដែលត្រូវកសាងសេដ្ឋកិច្ចរបស់ខ្លួន ដើម្បីលើកកំពស់ជីវភាពប្រជាជន ដោយពុំធ្វើឱ្យរចេរិលដល់បរិស្ថានរបស់ប្រទេសជាតិគេ ។

នៅប្រទេសជាច្រើនទូទាំងពិភពលោក គេបានធ្វើការស្រាវជ្រាវនានា ដើម្បីបង្កើនផលិតផល និងទំលាប់ប្រតិបត្តិថ្មីៗ ដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិច ហើយមិនប៉ះពាល់ដល់បរិស្ថាន ។ ឧទាហរណ៍មួយចំនួនគឺ :

- រថយន្តអ៊ីប្រីត និងរថយន្តដើរដោយអគ្គិសនី
- កំណែលំអមធ្យោបាយដឹកជញ្ជូនសាធារណៈ
- ការអភិវឌ្ឍន៍បច្ចេកវិទ្យាថាមពលកើតឡើងវិញ
- ការកែច្នៃ និងការប្រើប្រាស់ឡើងវិញ
- ការបង្កើតម៉ាស៊ីន និងបរិក្ខារដែលមានប្រសិទ្ធិភាពខ្ពស់
- ទំលាប់ប្រតិបត្តិប្រើប្រាស់ដីសមស្រប
- ការអភិរក្សព្រៃឈើ និងកិច្ចការពារបរិស្ថាន ។




*ព្រៃឈើស្រូបយកឧស្ម័ន $CO_2$ ពីបរិយាកាស*

ពិតមែនតែភាគច្រើននៃបច្ចេកវិទ្យា និងទំលាប់ប្រតិបត្តិទាំងនេះ មានលក្ខណៈប្រកួតប្រជែងខាងផ្នែកសេដ្ឋកិច្ច និងអាចទុកចិត្តបានក្តី ក៏ការអនុវត្តនីបច្ចេកវិទ្យា និងទំលាប់ប្រតិបត្តិទាំងនេះអាចទទួលជោគជ័យបាន លុះត្រាតែគេមានគោលនយោបាយថ្មី ការប្តេជ្ញាចិត្តផ្នែកនយោបាយ សមត្ថភាពបច្ចេកទេស និងសមត្ថភាពស្ថាប័នគ្រប់គ្រាន់ ព្រមទាំងការគាំទ្រជាសាធារណៈទូលំទូលាយ ។

បុគ្គលម្នាក់ៗអាចបំពេញតួនាទី ក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួនបាន ។ វិធានការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ភាគច្រើន ក៏ជួយផងដែរក្នុងការអភិរក្សធនធានធម្មជាតិ និងការកាត់បន្ថយការបញ្ចេញចោលសារធាតុនានា ដែលរួមចំណែកនាំឱ្យមានកង្វល់បរិស្ថានផ្សេងទៀត មានជាអាទិ៍ ផ្សែងលាយអ័ព្ទ ភ្លៀងអាស៊ីត និងការធ្លុះធ្លាយស្រទាប់អូសូន ។ ឧទាហរណ៍ខ្លះៗ ដែលសមស្របសំរាប់កម្ពុជា គឺ :

- កាត់បន្ថយតំរូវការប្រើប្រាស់ម៉ាស៊ីនត្រជាក់ ដោយបំពាក់ប្រដាប់បាំងពន្លឺ និង ដាំដើមឈើដែលផ្តល់ម្លប់នៅជិតគេហដ្ឋាន ឬបំពាក់ដោយរនាំង
- ប្រើប្រព័ន្ធកំដៅទឹកដើរដោយថាមពលព្រះអាទិត្យ
- នៅពេលទិញបរិក្ខារថ្មី ត្រូវធ្វើការប្រៀបធៀបអត្រាប្រើប្រាស់ថាមពល និងជ្រើសយកតែបរិក្ខារណាដែលស៊ីភ្លើងតិច ។ ទោះបីវាអាចថ្លៃជាងក្តី តែវាអាចជួយសន្សំសំចៃប្រាក់សំរាប់រយៈពេលវែង
- ប្រើប្រាស់អំពូលណេអុង (អំពូលម៉ែត) ជំនួសអំពូលពងមាន់ ។ ធ្វើបែបនេះអាចកាត់បន្ថយអត្រាប្រើប្រាស់អគ្គិសនីបាន 75%
- បិទភ្លើងនៅពេលពុំត្រូវការបំភ្លឺ
- ថែទាំរថយន្តឱ្យបានត្រឹមត្រូវ ដូចជាសំអាតឬប្តូរតំរងខ្យល់ សប់កង់រថយន្ត ក្នុងកំរិតសមស្រប ជៀសវាងការបន្ថែមបន្ទុកមិនចាំបាច់
- បើកបរដោយឈ្លាសវៃ គឺបើកបរដោយល្បឿនសមរម្យ ជៀសវាងការបញ្ឈប់ ឬបង្កើនល្បឿនភ្លាមៗ គ្រោងបើកបរតាមផ្លូវដែលផ្តល់ប្រសិទ្ធិភាពខ្ពស់ និងជៀសវាងការបញ្ឆេះម៉ាស៊ីនចោលរយៈពេលយូរ

- គួរពិចារណាជំរើសប្រើប្រាស់មធ្យោបាយដឹកជញ្ជូនសាធារណៈ
- ធ្វើដំណើរដោយធ្វើរជើង ឬកង់ សំរាប់ចំងាយផ្លូវជិត
- ចូលរួមនៅក្នុងយុទ្ធនាការកែច្នៃឡើងវិញ និងកិច្ចការពារបរិស្ថាន
- ដាំដើមឈើ
- ជូនដំណឹងទៅអ្នករៀបចំគោលនយោបាយ អំពីកង្វល់របស់ខ្លួនផ្នែកបរិស្ថាន និងជំរុញឱ្យកសាងផែនការធ្វើផ្លូវរវាងទីក្រុង និងផ្លូវសំរាប់កង់
- ដាំដើមឈើជិតផ្ទះសំរាប់ធ្វើអុស ដោយជៀសវាងកាប់ឈើពីព្រៃធ្វើអុស
- ចូលរួមក្នុងសកម្មភាពសហគមន៍ព្រៃឈើ ឬក្នុងយុទ្ធនាការអភិរក្សផ្សេងទៀត
- ពិចារណាលើការប្រើប្រាស់ជីវៈឧស្ម័ន (ឧស្ម័នពីលាមកសត្វ) សំរាប់ដាំស្លជំនួសការប្រើប្រាស់អុស
- សាកសួរស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលអំពីវិធីបង្កើនប្រសិទ្ធិភាពថាមពល ។

## ៦. បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

បន្សាំគឺជាលទ្ធភាពកែតំរូវរបស់មនុស្ស រុក្ខជាតិ ប្រព័ន្ធអេកូឡូស៊ី ។ល។ ទៅនឹងការប្រែប្រួលអាកាសធាតុ ដែលអាចកើតឡើងដោយឯកឯង ឬដោយគ្រោងទុកជាមុន ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ទាញយកកាលានុវត្តភាព ឬដោះស្រាយផលវិបាកនៃការប្រែប្រួលអាកាសធាតុ ។

ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ជាមធ្យោបាយសំខាន់ ក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ជាពិសេសសំរាប់រយៈពេលយូរអង្វែង រីឯបន្សាំអាចផ្តល់នូវដំណោះស្រាយភ្លាមៗ ទល់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាស-ធាតុ ដើម្បីកាត់បន្ថយការខូចខាត ។ ទោះបីជាកំហាប់ឧស្ម័នផ្ទះកញ្ចក់ក្នុងបរិយាកាសអាចត្រូវបានកាត់បន្ថយក្តី ក៏ការប្រែប្រួលអាកាសធាតុនឹងនៅតែបន្តកើតមាន ដោយសារតែនិចលភាពនៃប្រព័ន្ធអាកាសធាតុ និងវត្តមាននៃបរិមាណ

ឧស្ម័នផ្ទះកញ្ចក់ដ៏ច្រើនរួចមកហើយ ដែលបានបញ្ចេញចោលទៅក្នុងបរិយាកាសក្នុងអំឡុងពេលជាង 200 ឆ្នាំកន្លងទៅ ។

មានយុទ្ធសាស្ត្រទូទៅចំនួនប្រាំមួយ ដែលអាចយកមកប្រើប្រាស់បាន សំរាប់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ :

- *បញ្ចៀសការខូចខាត* ឧទាហរណ៍ : ការកសាងទំនប់ការពារទល់នឹងកំណើនកំពស់ទឹកសមុទ្រ
- *កាត់បន្ថយការខូចខាត* មកត្រឹមកំរិតដែលអាចធន់ទ្រាំបាន ។ ឧទាហរណ៍ ការប្រើប្រាស់ប្រភេទដំណាំសមស្រប ដើម្បីធានាឱ្យទទួលបាននូវទិន្នផលក្នុងកំរិតអប្បបរមាមួយ ទោះបីក្នុងលក្ខខណ្ឌអាកាសធាតុអាក្រក់បំផុតក៏ដោយ
- *ពង្រាយ ឬចែករំលែកការខូចខាត* ដោយសំរាលទុក្ខលំបាករបស់អ្នករងគ្រោះដោយផ្ទាល់ពីការប្រែប្រួលអាកាសធាតុ ដូចជាតាមរយៈជំនួយសង្គ្រោះរបស់រដ្ឋាភិបាលជាដើម
- *ផ្លាស់ប្តូរការប្រើប្រាស់ ឬសកម្មភាព* ដែលមិនអាចមានប្រសិទ្ធិភាពទៀតក្នុងលក្ខខណ្ឌអាកាសធាតុថ្មី
- *ប្តូរទីតាំង* នៃសកម្មភាពទៅកាន់កន្លែងសមស្របជាងមុន ឧទាហរណ៍ ការលើកទីតាំងរោងចក្រថាមពលវារីអគ្គីសនី ទៅកន្លែងដែលសំបូរទឹកជាង
- *ជួសជុលទីតាំងឡើងវិញ* ដូចជាទីកេរដំណែលប្រវត្តិសាស្ត្រដែលងាយខូចខាតដោយទឹកជំនន់ ។

សំរាប់វិស័យជាក់លាក់ណាមួយ វិធានការបន្សាំអាចមានដូចខាងក្រោម :

### ធនធានទឹក

ការគ្រប់គ្រងធនធានទឹកបានល្អ និងប្រកបដោយប្រសិទ្ធិភាពខ្ពស់ជាងមុន អាចជួយកាត់បន្ថយភាពងាយរងគ្រោះរបស់អ្នកប្រើប្រាស់ទឹក បណ្តាលមកពីផល

ប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ។ វិធានការបន្សាំមួយចំនួនដែលអាចយកមកប្រើប្រាស់បានគឺ ការរៀបចំបទបញ្ញត្តិនិងអភិវឌ្ឍន៍បច្ចេកវិទ្យាសំរាប់គ្រប់គ្រងដោយផ្ទាល់លើការប្រើប្រាស់ដីនិងទឹក ការលើកទឹកចិត្តផ្នែកសេដ្ឋកិច្ចដើម្បីឱ្យអ្នកប្រើប្រាស់ផ្លាស់ប្តូរឥរិយាបទ ការស្វែងរកប្រភពទឹកថ្មីៗ ការកែលំអប្រតិបត្តិការនិងស្ថាប័នគ្រប់គ្រងទឹក កិច្ចការពារទីជំរាល កិច្ចការពាររុក្ខជាតិតាមមាត់ទឹក ការស្តារផ្លូវទឹកទន្លេមកស្ថានភាពធម្មជាតិដើមវិញ និងការកាត់បន្ថយការបំពុលទឹក ។

## កសិកម្ម

ការអនុវត្តន៍គោលនយោបាយ និងផែនការបន្សាំប្រកបដោយប្រសិទ្ធិភាពអាចជួយកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ទៅលើផលិតភាពកសិកម្ម ឬជួយលើកកំពស់សន្តិសុខស្បៀង ។ ផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុអាចត្រូវកាត់បន្ថយបានតាមរយៈ : ការប្តូរមុខដំណាំ និងពូជដំណាំ ការកែលំអប្រព័ន្ធគ្រប់គ្រងទឹកនិងប្រព័ន្ធស្រោចស្រព ការដាំដំណាំនិងការភ្ជួរដីតាមកាលវេលាកំណត់ ការកែលំអការគ្រប់គ្រងទីជំរាលនិងការធ្វើផែនការប្រើប្រាស់ដី ។

## សុខភាពមនុស្ស

ហានិភ័យចំពោះសុខភាពមនុស្ស បណ្តាលមកពីការប្រែប្រួលអាកាសធាតុអាចកាត់បន្ថយបាន តាមរយៈយុទ្ធសាស្ត្របន្សាំផ្សេងៗ ។ ចំពោះប្រទេសដែលមានសមត្ថភាពបន្សាំទាប និងធនធានតិច ដូចកម្ពុជាជាដើម ចាំបាច់ត្រូវផ្តល់អាទិភាពដល់បណ្តាវិធានការការពារជាមុន ដើម្បីកាត់បន្ថយតំរូវការអនុវត្តន៏វិធានការតបត និងការព្យាបាល ដែលត្រូវចំណាយច្រើន ។ វិធានការបន្សាំដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ចំពោះសុខភាពមនុស្សអាចជា : ការលើកកំពស់សេវាវេជ្ជសាស្ត្រថែទាំ (ពិសេសសំរាប់ជម្ងឺឆ្លង) កម្មវិធីត្រួតពិនិត្យសុខភាព និងអនាម័យ ការបង្កើនការអប់រំនិងការយល់ដឹងសាធារណៈ

ការកែលំអការគ្រប់គ្រងបរិស្ថាន ការត្រៀមបង្ការគ្រោះមហន្តរាយ ការលើកកំពស់ការត្រួតពិនិត្យទឹកនិងការបំពុល ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការស្រាវជ្រាវ និងបច្ចេកវិទ្យាការពារជាមុន (ដូចជា ការកែលំអសំណង់លំនៅដ្ឋាន ការបន្សុទ្ធទឹក និងការផ្តល់ថ្នាំបង្ការ) ។

## តំបន់ឆ្នេរ

បណ្តាជំរើសឆ្លើយតបទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដែលអាចយកមកអនុវត្តបាននៅតំបន់ឆ្នេររួមមាន ការសាងសង់កំពែងនិងទំនប់ការពារទឹកសមុទ្រ ការបង្កើតតំបន់ដីសើម ការអនុម័តកូដសំណង់ថ្មី កិច្ចការពារប្រព័ន្ធអេកូឡូស៊ីដែលស្ថិតនៅក្រោមការគំរាមកំហែង ការដាក់តែងបទបញ្ញត្តិនិងផែនការសំរាប់ការអភិវឌ្ឍន៍តំបន់ឆ្នេរថ្មីៗ ការកែលំអស្តង់ដាគំនូរប្លង់ និងការពង្រឹងការគ្រប់គ្រងជលផល ។ ការគ្រប់គ្រងតំបន់ឆ្នេរបែបសមាហរណកម្ម ដែលយកមកពិចារណានូវបណ្តាវិធានការសង្គម សេដ្ឋកិច្ច ច្បាប់ ស្ថាប័ន និងបរិស្ថាន អាចផ្តល់នូវបណ្តាជំរើសឆ្លើយតបយ៉ាងទូលំទូលាយច្រើនយ៉ាង ។

## ព្រៃឈើ និងប្រព័ន្ធអេកូឡូស៊ី

ក្នុងវិស័យព្រៃឈើ បណ្តាវិធានការដែលអាចជួយប្រព័ន្ធអេកូឡូស៊ីធម្មជាតិឱ្យបន្សាំនឹងការប្រែប្រួលអាកាសធាតុ អាចរាប់បញ្ចូល : ការបង្កើតរបៀងសំរាប់ការផ្លាស់ទីដោយធម្មជាតិ និងការជួយប្រភេទខ្លះៗក្នុងការផ្លាស់ទី ការដាំព្រៃឡើងវិញ វិធានការចំរុះគ្រប់គ្រងភ្លើងព្រៃ កត្តាចង្រៃ និងជំងឺ ការជ្រើសរើសប្រភេទរុក្ខជាតិសមស្របសំរាប់ដីចិញ្ចឹមសត្វ ការត្រួតពិនិត្យចំនួនសត្វដាក់ចិញ្ចឹម យុទ្ធសាស្ត្រថ្មីសំរាប់ការលែងសត្វឱ្យស៊ីស្មៅ ការដាំប្រភេទរុក្ខជាតិធន់នឹងភាពរាំងស្ងួត និងការអនុវត្តន៍កិច្ចអភិរក្សដីដែលប្រសើរជាងមុន ។

**គ្រោះមហន្តរាយអាកាសធាតុ និងបាតុភូតអាកាសធាតុមិនប្រក្រតី**

ហានិភ័យបង្កដោយគ្រោះមហន្តរាយ និងអាកាសធាតុមិនប្រក្រតី អាចត្រូវកាត់បន្ថយបាន តាមរយៈការធ្វើផែនការត្រៀមបង្ការគ្រោះមហន្តរាយ ការផ្សព្វ-ផ្សាយព័ត៌មាន និងការបង្កើនការយល់ដឹងឱ្យបានប្រសើរ ការបង្កើនសមត្ថភាពបច្ចេកទេសនិងសមត្ថភាពស្ថាប័នសំរាប់បណ្តាទីភ្នាក់ងារទទួលខុសត្រូវ ការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ (អគារ ការដឹកជញ្ជូន ការស្រោចស្រព ។ល។) ។

## ៧. សកម្មភាពក្នុងវិស័យប្រែប្រួលអាកាសធាតុនៅកម្ពុជា

**កម្ពុជា និងអនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ**

ក្នុងនាមជាប្រទេសក្រីក្រមួយ កម្ពុជាទទួលស្គាល់ការប្រែប្រួលអាកាសធាតុថាជាការគំរាមកំហែងផ្នែកបរិស្ថានយ៉ាងធ្ងន់ធ្ងរ ចំពោះប្រទេសជាតិ និងពិភពលោកទាំងមូល ។ ជាមួយសមត្ថភាព និងធនធានមានកំរិតរបស់ខ្លួន រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការយ៉ាងសកម្មជាមួយសហគមន៍អន្តរជាតិ ដើម្បីឆ្លើយតបនឹងការគំរាមកំហែងនេះ ។

ប្រទេសកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញា ស្តីពីការប្រែប្រួលអាកាសធាតុនៅឆ្នាំ 1995 ពោលគឺតែក្នុងរយៈពេលពីរឆ្នាំ ក្រោយការបង្កើតក្រសួងបរិស្ថាន និងការបោះឆ្នោតជាតិលើកទីមួយរបស់ខ្លួន គិតតាំងពីទសវត្សរ៍ឆ្នាំទី 70 មក ។ នៅខែកញ្ញា ឆ្នាំ 2002 កម្ពុជា បានចេញរបាយការណ៍ជាតិលើកទីមួយរបស់ខ្លួនក្រោមអនុសញ្ញានេះ ដែលបង្ហាញពីលទ្ធផលនៃការធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិសំរាប់ឆ្នាំ 1994 ការព្យាករណ៍ឧស្ម័នផ្ទះកញ្ចក់ពីឆ្នាំ 1994 ដល់ឆ្នាំ 2020 ជំរើសនានាសំរាប់កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការវាយតំលៃភាពងាយរងគ្រោះ និងបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ ។

សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់បានបង្ហាញថា នៅឆ្នាំ 1994 កម្ពុជាគឺជាប្រទេសស្រូបកាបូនច្រើនជាងបញ្ចេញ ដោយបានស្រូបយកកាបូនចំនួន 5,142 លានតោនគិតជាសមមូល $CO_2$ ។ ការប្រែប្រួលនៃការប្រើប្រាស់ដី និងព្រៃឈើ (land use

change and forestry: LUCF) គឺជាវិស័យដែលបានបញ្ចេញ និងស្រូបយកឧស្ម័នផ្ទះកញ្ចក់ច្រើនជាងគេ ក្នុងឆ្នាំ 1994 ។ វិស័យនេះបានបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងបរិមាណ 81,2% នៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុប បន្ទាប់មកគឺវិស័យកសិកម្មដែលបញ្ចេញ 15,5% ហើយវិស័យថាមពលបញ្ចេញ 2,8% នៃបរិមាណឧស្ម័នផ្ទះកញ្ចក់ដែលបានបញ្ចេញសរុប ។

ក្នុងនាមជាប្រទេសក្រីក្រមួយ កម្ពុជាបានទទួលហិរញ្ញប្បទានពីមូលនិធិបរិស្ថានពិភពលោក (Global Environment Facility: GEF) សំរាប់រៀបចំកម្មវិធីសកម្មភាពជាតិដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (National Adaptation Program of Action to Climate Change: NAPA) ។ គំរោងនេះបានចាប់ផ្តើមនៅពាក់កណ្តាលឆ្នាំ 2003 និងរំពឹងថាបញ្ចប់នៅចុងឆ្នាំ 2004 ។ កម្មវិធីសកម្មភាពជាតិនេះ រួមមានបណ្តុំគំរោងអាទិភាពនានា ដែលឆ្លើយតបទៅនឹងតំរូវការ និងកង្វល់ចំពោះមុខជាបន្ទាន់របស់ប្រទេសកម្ពុជា ក្នុងការបន្សាំទៅនឹងឥទ្ធិពលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ក្នុងវិស័យកសិកម្ម ធនធានទឹក តំបន់ឆ្នេរ ព្រៃឈើ និងសុខភាពមនុស្ស ។

## កម្ពុជា និងយន្តការអភិវឌ្ឍន៍ស្អាត

ជាប្រទេសកំពុងអភិវឌ្ឍន៍ និងជាភាគីមិនស្ថិតក្នុងឧបសម្ព័ន្ធ 1 នៃអនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ កម្ពុជាមិនមានជាប់កាតព្វកិច្ចដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ឡើយ ។ ប៉ុន្តែ ប្រទេសកម្ពុជាបានប្តេជ្ញាគាំទ្រការប្រកាសឱ្យប្រើពិធីសារក្យូតូ ជាកិច្ចព្រមព្រៀងអន្តរជាតិទីមួយ ដែលជាមូលដ្ឋានគ្រឹះសំរាប់ឈានទៅសំរេចគោលដៅចុងក្រោយ នៃអនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុពោលគឺ ធ្វើឱ្យមានតុល្យភាពកំហាប់ឧស្ម័នផ្ទះកញ្ចក់ក្នុងបរិយាកាស ត្រឹមកំរិតមួយដែលទប់ស្កាត់ការប្រែប្រួលប្រកបដោយគ្រោះថ្នាក់ចំពោះប្រព័ន្ធអាកាសធាតុ ។

ក្នុងបរិបទនេះ រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើលិខិតុបករណ៍សុំចូលជាសមាជិកនៃពិធីសារក្យូតូនៅថ្ងៃទី 4 ខែកក្កដា ឆ្នាំ 2002 ដែលបង្ហាញពីការ

ប្តេជ្ញាចិត្តរបស់ខ្លួនចំពោះកិច្ចប្រឹងប្រែងជាសកល ក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ។ ប្រការនេះធ្វើឱ្យប្រទេសកម្ពុជាអាចមានសិទ្ធិធ្វើជាម្ចាស់ផ្ទះនៃគំរោងកាត់បន្ថយការបញ្ចេញឧស្ម័នក្រោមយន្តការអភិវឌ្ឍន៍ស្អាត (the Clean Development Mechanism: CDM) ។

CDM មានគោលដៅគន្លឹះពីរ គឺ (១) ជួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលជាម្ចាស់ផ្ទះនៃគំរោង CDM ដើម្បីសំរេចគោលដៅអភិវឌ្ឍន៍ដោយចីរភាពរបស់ខ្លួន និង (២) ជួយប្រទេសជឿនលឿនក្នុងការបំពេញកាតព្វកិច្ចកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់ខ្លួនមួយផ្នែក ដោយអនុញ្ញាតឱ្យប្រទេសទាំងនោះទទួលយកឥណទានកាបូនពីគំរោងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ដែលបានអនុវត្តន៍ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។




*គំនូសតាងសង្ខេបនៃយន្តការអភិវឌ្ឍន៍ស្អាត*

ដើម្បីចូលរួមក្នុង CDM ប្រទេសកំពុងអភិវឌ្ឍន៍ត្រូវបំពេញលក្ខខណ្ឌបីជាមូលដ្ឋានគឺ : (១) ការចូលរួមដោយស្ម័គ្រចិត្ត (២) ការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត (Designated National Authority: DNA) និង (៣) ការផ្តល់សច្ចាប័នដល់ពិធីសារក្យូតូ ។ CDM មិនអាចបង្វែរជំនួយអភិវឌ្ឍន៍ផ្លូវការ (Official Development Assistance: ODA) បានទេ ។ អាជ្ញាធរជាតិមានភារៈទទួលខុសត្រូវចេញសេចក្តីបញ្ជាក់ថា សំណើគំរោង CDM បំពេញគោលដៅអភិវឌ្ឍន៍ជាតិដោយចីរភាព ។

ប្រភេទគំរោង CDM តួយ៉ាងខ្លះ ដែលកាត់បន្ថយ ជៀសវាង ឬស្រូបឧស្ម័នផ្ទះកញ្ចក់ គឺ :

- ថាមពលកើតឡើងវិញ (វារីអគ្គិសនី ខ្យល់ ព្រះអាទិត្យ ជីវៈម៉ាស)
- ប្រសិទ្ធិភាពថាមពល (ការផលិត និងការប្រើប្រាស់)
- ការប្តូរឥន្ធនៈ (ជីវៈម៉ាស៊ូត ឧស្ម័ន)
- ការផលិតកំដៅ និងថាមពលក្នុងពេលតែមួយ (cogeneration)
- ដំណើរការផលិតកម្មឧស្សាហកម្ម (ឧទាហរណ៍ : $CO_2$ ពីផលិតកម្មស៊ីម៉ងត៍)
- ព្រៃឈើ (ការដាំព្រៃឈើ និងការស្តារព្រៃឈើឡើងវិញ សំរាប់ជាអាងផ្ទុកកាបូន)
- សកម្មភាពដឹកជញ្ជូន
- ការគ្រប់គ្រងសំណល់ ។

## ផលចំណេញនៃ CDM សំរាប់កម្ពុជា

សំរាប់ប្រទេសកម្ពុជា CDM អាចជាប្រភពនៃការវិនិយោគថ្មី បច្ចេកវិទ្យាមិនបំផ្លាញបរិស្ថាន និងការកសាងសមត្ថភាព ក្នុងវិស័យថាមពល ព្រៃឈើ កសិកម្ម និងការគ្រប់គ្រងសំណល់ ។ ទាំងនេះគឺជាវិស័យសេដ្ឋកិច្ចគន្លឹះមួយចំនួន ដែលកម្ពុជាត្រូវការពង្រឹង ដើម្បីទ្រទ្រង់គោលដៅអភិវឌ្ឍន៍ដោយចិរភាពរបស់ខ្លួន ។ ក្នុងវិស័យថាមពល ប្រសិនបើគេធ្វើការរៀបចំប្លង់ និងអនុវត្តន៍គំរោង CDM ដោយឈ្លាសវៃ នោះបណ្តាគំរោងទាំងនោះនឹងផ្តល់កាលានុវត្តភាពដល់ប្រទេសជាតិ ក្នុងការលើកកំពស់ប្រសិទ្ធិភាពថាមពល ការអភិវឌ្ឍន៍ថាមពលកើតឡើងវិញដែលមានក្នុងស្រុក ការផ្ទេរបច្ចេកវិទ្យាដែលមិនបំផ្លាញបរិស្ថាន និងការជួយបង្កើតការងារថ្មីៗ ។

ក្នុងវិស័យព្រៃឈើ គំរោង CDM នឹងជួយបង្កើនបរិមាណព្រៃឈើ តាមរយៈការដាំព្រៃឈើ និងការស្តារព្រៃឈើឡើងវិញ ។ ជាលទ្ធផល ព្រៃឈើទាំងនេះនឹង

ជួយកែតំរូវអាកាសធាតុប្រចាំទី កាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាស-ធាតុ ដូចជាទឹកជំនន់និងខ្យល់ព្យុះ ព្រមទាំងស្រូបកាបូនពីបរិយាកាស ។ លើសពីនេះ គំរោង CDM នឹងផ្តល់នូវអត្ថប្រយោជន៍ និងសេវាបរិស្ថានពាក់ព័ន្ធជាច្រើនទៀត ដូចជាការពារទីជំរាល ការពារសំណើក និងការចេរីលដី អភិរក្សជីវៈចំរុះ និងផ្តល់អនុផលព្រៃឈើ ។ ទាំងនេះគឺជាទិដ្ឋភាពសំខាន់បំផុតសំរាប់សហគមន៍មូលដ្ឋាន និងសំរាប់ប្រទេសកម្ពុជាទាំងមូល ។

## សក្តានុពលគំរោង CDM នៅកម្ពុជា

មកទល់បច្ចុប្បន្ន ការអភិវឌ្ឍន៍វិស័យថាមពលនៅប្រទេសកម្ពុជាបានពឹងផ្អែកជាមូលដ្ឋានលើបច្ចេកវិទ្យាប្រពៃណី ដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់ច្រើន ហើយច្រើនតែជាបច្ចេកវិទ្យាហួសសម័យ ដូចជាម៉ាស៊ីនភ្លើងដើរដោយប្រេងខ្មៅ និងប្រេងម៉ាស៊ូត ជាដើម ។ នៅតំបន់ជនបទ អុសនៅតែជាប្រភពថាមពលចំបងសំរាប់រយៈពេលជាច្រើនឆ្នាំទៅមុខទៀត ។ ប្រសិទ្ធិភាពនៃការប្រើប្រាស់ថាមពលទាំងក្នុង និងក្រៅវិស័យពាណិជ្ជកម្មបច្ចុប្បន្ន នៅមានកំរិតទាបនៅឡើយ ។ ដូច្នេះ CDM មានសក្តានុពលច្រើន ដែលអាចផ្តល់ឱ្យតាមរយៈការជំរុញបង្កើតបណ្តុំគំរោងថាមពលនិរន្តរភាព ។

ថ្មីៗនេះ គំរោង *ការពង្រឹងសមត្ថភាពចំរុះសំរាប់យន្តការអភិវឌ្ឍន៍ស្អាត* (Integrated Capacity Strengthening for the Clean Development Mechanism) ដែលផ្តល់ហិរញ្ញប្បទានដោយ វិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានពិភពលោកនៃប្រទេសជប៉ុន បានឧបត្ថម្ភដល់ការសិក្សាមួយស្តីពីសក្តានុពលសំរាប់បណ្តុំគំរោងថាមពលនិរន្តរភាពថាមពល (ពោលគឺថាមពលកើតឡើងវិញ និងប្រសិទ្ធិភាពថាមពល) នៅប្រទេសកម្ពុជា ។ ភាគច្រើននៃគំរោង ដែលបានកំណត់នៅក្នុងការសិក្សានេះជាគំរោងវារីអគ្គិសនីខ្នាតតូច គំរោងជីវៈម៉ាស គំរោងថាមពលខ្យល់ និងគំរោងថាមពលព្រះអាទិត្យ ។ ការសិក្សានោះបង្ហាញថា ប្រសិនបើបានអនុវត្ត គំរោងទាំងនោះអាចកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប្រមាណ 47 លានតោនក្នុងមួយឆ្នាំ ។



*បន្ទះកញ្ចក់ស្រូបពន្លឺព្រះអាទិត្យ នៃរោងចក្រអគ្គិសនីដើរដោយថាមពលព្រះអាទិត្យ និងជីវៈឧស្ម័ន កំលាំង 120 kW នៅក្បែរក្រុងព្រះសីហនុ*

នៅក្នុងវិស័យព្រៃឈើ ពុំទាន់មានការសិក្សាលំអិតនៅឡើយទេ ដើម្បីវាយតំលៃសក្តានុពល CDM ។ ប៉ុន្តែ គេជឿថា វិស័យនេះអាចផ្តល់កាលានុវត្តភាពដ៏សន្ធឹកសន្ធាប់ សំរាប់ស្តារព្រៃឈើ នៅតាមទីកន្លែងដែលបានបាត់បង់ព្រៃឈើតាំងពីមុនឆ្នាំ 1990 ដូចមានចែងក្នុងវិធាន CDM សំរាប់វិស័យព្រៃឈើ ។ កសិ-រុក្ខកម្ម និងសហគមន៍ព្រៃឈើក៏ជាប្រភេទគំរោងដែលមានសិទ្ធិទទួលជាគំរោង CDM ផងដែរ ។

## ការរៀបចំផ្នែកស្ថាប័ន CDM នៅកម្ពុជា

ការិយាល័យប្រែប្រួលអាកាសធាតុនៃប្រទេសកម្ពុជា ត្រូវបានបង្កើតឡើងនៅខែមិថុនា ឆ្នាំ 2003 ចំណុះឱ្យក្រសួងបរិស្ថាននៃប្រទេសកម្ពុជា ។ ការិយាល័យនេះទទួលខុសត្រូវលើសកម្មភាពជាច្រើនពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ដូចជា ការរៀបចំផែនការនិងគោលនយោបាយ ការអនុវត្តន៏កាតព្វកិច្ចរបស់ប្រទេសក្រោម UNFCCC ការវាយតំលៃបច្ចេកវិទ្យាថ្មីសំរាប់បន្សុំាទៅនឹងឥទ្ធិពល

អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ឬកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការកសាងសមត្ថភាព និងការលើកកំពស់ការយល់ដឹង ។ ការិយាល័យនេះក៏មាននាទីជាលេខាធិការដ្ឋាននៃជនបង្គោលរបស់ UNFCCC ពិធីសារក្យូតូ និង CDM សំរាប់ប្រទេសកម្ពុជាផងដែរ ។

នៅខែកក្កដា ឆ្នាំ 2003 សម្តេចនាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា បានតែងតាំងក្រសួងបរិស្ថានជាស្ថាប័នបណ្តោះអាសន្ន (Interim Designated National Authority: DNA) ទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត ។ ក្នុងនាមជាស្ថាប័ននេះ ក្រសួងបរិស្ថានទទួលខុសត្រូវលើការវាយតំលៃសំណើគំរោង CDM ដោយផ្អែកលើគោលដៅអភិវឌ្ឍន៍ដោយចីរភាពនៃប្រទេសជាតិ ។ លើសពីនេះ ក្រសួងបរិស្ថាននឹងទទួលខុសត្រូវក្នុងការចេញលិខិតអនុម័តសំរាប់គ្រប់គំរោង CDM ដោយបញ្ជាក់ថា ក្នុងនាមជាប្រទេសម្ចាស់ផ្ទះ កម្ពុជាចូលរួមដោយស្ម័គ្រចិត្តក្នុងការអនុវត្តន៍ CDM ព្រមទាំងថា សំណើគំរោងនោះនឹងជួយឱ្យសំរេចគោលដៅអភិវឌ្ឍន៍ជាតិដោយចីរភាព ។ នៅក្នុងសមត្ថកិច្ចរបស់ខ្លួនជា DNA បណ្តោះអាសន្ន ក្រសួងបរិស្ថានធ្វើការជាមួយក្រសួងផ្សេងទៀតរបស់រាជរដ្ឋាភិបាល ផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីវាយតំលៃ និងអនុម័តគំរោង ។ ក្រសួងបរិស្ថាននឹងដើរតួផងដែរជាការិយាល័យទាក់ទង និងជាជនបង្គោល សំរាប់ការងារទំនាក់ទំនងជាតិ និងអន្តរជាតិ ពាក់ព័ន្ធនឹង CDM និងជំរុញ ព្រមទាំងសំរបសំរួលការវិនិយោគលើគំរោង CDM នៅប្រទេសកម្ពុជា ។

បច្ចុប្បន្ន ការិយាល័យប្រែប្រួលអាកាសធាតុកំពុងសហការជាមួយក្រសួងពាក់ព័ន្ធដទៃទៀត ដើម្បីបង្កើតស្ថាប័នជាតិ DNA អចិន្ត្រៃយ៍មួយ បង្ហើយការរៀបចំរចនាសម្ព័ន្ធរបស់ខ្លួន គោលការណ៍ប្រតិបត្តិ និងលក្ខណៈវិនិច្ឆ័យនៃការអភិវឌ្ឍន៍ដោយចីរភាព សំរាប់វាយតំលៃសំណើគំរោង CDM ។ គេរំពឹងថា នៅក្នុងរចនាសម្ព័ន្ធចុងក្រោយនៃ DNA ការិយាល័យប្រែប្រួលអាកាសធាតុនឹងមាននាទី ជាលេខាធិការដ្ឋានរបស់ DNA ដើម្បីសំរបសំរួលការវាយតំលៃលើសំណើគំរោង CDM ធ្វើការជាមួយក្រុមការងារអន្តរក្រសួងសំរាប់វិស័យថាមពលនិង

ព្រៃឈើ សំរបសំរួលការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងលើកអនុសាសន៍ទៅជូន DNA ។ DNA របស់កម្ពុជានាពេលអនាគតទំនងជាមានសមាសភាពមកពីអន្តរក្រសួង ព្រមទាំងធ្វើការអនុម័តឯកភាព ឬបដិសេធសំណើគំរោង CDM ដោយ ផ្អែកលើអនុសាសន៍ពីលេខាធិការដ្ឋាន និងក្រុមការងារអន្តរក្រសួង ។ គេរំពឹងថា សេចក្តីព្រាងសំរេចនៃរចនាសម្ព័ន្ធរបស់ DNA នឹងត្រូវធ្វើជូនទៅគណៈរដ្ឋមន្ត្រី នៅមុនដំណាច់ឆ្នាំ 2004 ។

ក្នុងការត្រៀមខ្លួនសំរាប់ CDM កម្ពុជាកំពុងអនុវត្តគំរោងកសាងសមត្ថភាពមួយចំនួន ដែលក្នុងនោះរួមមាន ការគាំទ្រពីក្រសួងបរិស្ថាននៃប្រទេសជប៉ុន តាមរយៈវិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានពិភពលោក (Institute of Global Environmental Strategies: IGES) ។

តាមរយៈគំរោងទាំងនេះ ប្រទេសកម្ពុជានឹងបង្កើនការយល់ដឹងអំពី CDM នៅថ្នាក់ជាតិនិងថ្នាក់ខេត្ត ពង្រឹងសមត្ថភាព CDM សំរាប់អ្នករៀបចំគោលនយោបាយផ្នែកឯកជននិងសាធារណៈ រៀបចំលក្ខណៈវិនិច្ឆ័យស្តីពីការអភិវឌ្ឍន៍ដោយចីរភាពសំរាប់វាយតំលៃសំណើគំរោង CDM បង្កើត DNA អចិន្ត្រៃយ៍ រៀបចំបែបបទសំរាប់វាយតំលៃសំណើគំរោង CDM កសាងបញ្ជីគំរោង CDM និងជំរុញឱ្យមានការអនុវត្តន៍គំរោងទាំងនេះ ក្នុងចំណោមក្រុមហ៊ុនអភិវឌ្ឍន៍ និងវិនិយោគិន ។

ស្ថាប័នបណ្តោះអាសន្នទទួលបន្ទុកយន្តការអភិវឌ្ឍស្អាត មានទីតាំងស្ថិតនៅក្នុងការិយាល័យប្រែប្រួលអាកាសធាតុ នៃក្រសួងបរិស្ថាន អាគារលេខ 48 មហាវិថីសម្តេចព្រះសីហនុ ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

# សន្ទានុក្រម

| | |
|---|---|
| Adaptation | បន្សាំ |
| Assigned Amount Unit | ឯកតាបរិមាណដែលបានកំណត់ |
| Baseline | គោល, លក្ខខណ្ឌគោល |
| Baseline emission | ការបញ្ចេញឧស្ម័នគោល |
| Certified Emission Reduction (CER) | ការកាត់បន្ថយឧស្ម័នដែលបានបញ្ជាក់ |
| Clean Development Mechanism (CDM) | យន្តការអភិវឌ្ឍន៍ស្អាត |
| Climate change | ការប្រែប្រួលអាកាសធាតុ |
| Climate system | ប្រព័ន្ធអាកាសធាតុ |
| Common but differentiated responsibilities | ការទទួលខុសត្រូវរួមគ្នា តែមានកំរិតផ្សេងៗគ្នា |
| Conference of the Parties (CoP) | សន្និសីទបណ្តាភាគី |
| Crediting period | អំឡុងពេលឥណទាន |
| Eligibility | ភាពអាចជ្រើសរើសយកបាន, ភាពមានសិទ្ធិទទួល |
| Emission | ការបញ្ចេញឧស្ម័ន |
| Emission Reduction Unit | ឯកតាកាត់បន្ថយការបញ្ចេញឧស្ម័ន |
| Emission Trading | ការធ្វើពាណិជ្ជកម្មនៃឥណទានការបញ្ចេញឧស្ម័ន |
| Global warming | កំណើនកំដៅសកល |
| Greenhouse effect | ផលផ្ទះកញ្ចក់ |
| Greenhouse gas (GHG) | ឧស្ម័នផ្ទះកញ្ចក់ |
| Inertia | និចលភាព |
| Intergovernmental Panel on Climate Change (IPCC) | ក្រុមការងារអន្តររដ្ឋាភិបាល ស្តីពីការប្រែប្រួលអាកាសធាតុ |
| Join Implementation (JI) | ការអនុវត្តន៍រួមគ្នា |
| Legally binding commitment | ការសន្យាជាលក្ខណៈច្បាប់ |

| | |
|---|---|
| Mitigation | ការសំរាល, ការបន្ធូរបន្ថយ, ការកាត់បន្ថយ |
| National Communication | របាយការណ៍ជាតិ |
| Operational Entity | អង្គភាពប្រតិបត្តិ |
| Precipitation | កំណកអាកាស |
| Quantified emission limitation and reduction commitments | ការសន្យាកំហិត និងកាត់បន្ថយបរិមាណការបញ្ចេញឧស្ម័ន |
| Reservoir | អាងផ្ទុកកាបូន |
| Sink | អាងស្រូបកាបូន |
| Uncertainty | ភាពមិនប្រាកដប្រជា |
| United Nations Environment Programme (UNEP) | កម្មវិធីបរិស្ថានសហប្រជាជាតិ |
| Validation | ការផ្តល់សុពលភាព |
| World Meteorological Organisation | អង្គការឧតុនិយមពិភពលោក |

# ឯកសារយោង

Climate Change Secretariat. A Guide to the Climate Change Convention and its Kyoto protocol. Bonn, 2002.

Climate Change Secretariat. A Guide to the Climate Change Convention Process. Bonn, 2002.

Foundation for the Philippine Environment. Cool Practices for Hot Climate. The Philippines, 2000.

Louise Aukland *et al*. Laying the Foundations for Clean Development: Preparing the Land Use Sector, A Quick Guide to the Clean Development Mechanism. London, 2002.

Ministry of Environment. Cambodia's Initial National Communication under the United Frameworks Convention on Climate Change, Phnom Penh, 2002.

Noelle O'Brien *et al.* Environment: Concepts and Issues, A Focus on Cambodia, Phnom Penh, 1998.

Peter Denton. The Climate in Crisis, WWF, 1997.

The Pembina Institute. A User's Guide to the Clean Development Mechanism, Canada, 2002.

UNEP. Climate Change information Sheets, Switzerland, 1997.

UNEP/WMO. Common Questions about Climate Change, Kenya, undated.

UNEP/WMO. Understanding Climate Change: A Beginner's Guide to the UN Framework Convention, Switzerland, 1995.